# អំពើល្អចំពោះឪពុកម្តាយ

# بر الوالدين

## ការស្វែងយល់អំពី

# ការគោរពប្រតិបត្តិចំពោះមាតាបិតា

**រៀបចំដោយគណៈកម្មការបកប្រែ និងបោះពុម្ពសៀវភៅ**
**នៃសមាគមសំរបសំរួលសង្គមនៃប្រទេសគុយវែត**
**សហការជាមួយសមាគមសប្បុរសធម៌ដើម្បីអភិវឌ្ឍន៍កម្ពុជា**



## អារម្ភកថា

មិត្តអ្នកអានទាំងឡាយជាទីមេត្រី! នេះជាសមិទ្ធិផលថ្មីមួយទៀតដែលក្រុមយើងខ្ញុំបានដកស្រង់ និងប្រែសំរួលអត្ថបទនេះជាខេមរៈភាសានូវអត្ថបទមានចំណងជើងថា " **ការគោរពប្រតិបត្តិចំពោះមាតាបិតា**" ។

មាតាបិតាគឺជាអ្នកមានគុណដ៏មហាសែនធ្ងន់បំផុតសំរាប់បុត្រធិតាគ្រប់រូបដែលមិនអាចយកអ្វីមកកាត់ថ្លៃបាន ។ ច្បាប់អ៊ីស្លាមបានដាក់កាតព្វកិច្ចដល់បុគ្គលគ្រប់រូបត្រូវគោរពប្រតិបត្តិ និងមានកតញ្ញូចំពោះមាតាបិតាមិនអាចធ្វេសប្រហែសបានឡើយ ។ នេះជាអត្ថបទមួយបង្ហាញនូវច្បាប់អ៊ីស្លាមដែលពាក់ព័ន្ធបញ្ហាកតញ្ញូចំពោះមាតាបិតានិងផលបុណ្យរបស់វា ហើយក៏បានលើកបង្ហាញពីទោសកំហុសពីការធ្វើចំពោះលោកទាំងពីរដែរ ។

សង្ឃឹមថាអត្ថបទនេះនឹងមានសារប្រយោជន៍ដល់មិត្តអ្នកអាន និងជនមូស្លីមគ្រប់រូបក្នុងការប្រតិបត្តិចំពោះមាតាបិតារបស់ខ្លួន ។

យើងខ្ញុំរង់ចាំរាល់ការរិះគន់ស្ថាបនាពីសំណាក់មិត្តអ្នកអានគ្រប់ពេល ។

សូមបួងសួងពីអល់ឡោះ ចង្អុលបង្ហាញដល់ពួកយើងខ្ញុំនិងមិត្តអ្នកអាននូវមាគ៌ាសច្ចៈសុច្ចរិតពីលោកីយ៍រហូតដល់បរលោក ។

**សូមអរគុណ**

**មាតិកាអត្ថបទ** **ទំព័រ**


ការគោរពប្រតិបត្តិចំពោះឪពុកម្តាយបញ្ជាក់នៅក្នុងគម្ពីរអាល់គួរអាន ..............................................................................០៤
កិច្ចការប្រាំយ៉ាងដែលត្រូវគោរពតាមលោកទាំងពីរ.......................០៧
លក្ខខណ្ឌចំពោះការធ្វើអំពើល្អដល់មាតាបិតា ..............................១០
ឧត្តមភាពចំពោះការគោរពប្រតិបត្តិមាតាបិតា............................១១
កិច្ចការមួយចំនួនដែលត្រូវកំណត់លើការធ្វើអំពើល្អ......................២៣
ការធ្វើល្អចំពោះមាតាបិតា .....................................................២៨
ប្រវត្តិរឿងអំពីការគោរពប្រតិបត្តិចំពោះមាតាបិតានៃមនុស្សជំនាន់មុនៗ..........................................................................៣៦
អំពើអកតញ្ញូចំពោះមាតាបិតា..................................................៤១
ការបង្ហាញអំពីការអកតញ្ញូចំពោះមាតាបិតា..............................៤៣
កម្មផលរបស់ជនធ្វើអំពើអកតញ្ញូចំពោះមាតាបិតា......................៤៩
ប្រវត្តិរឿងជនអកតញ្ញូមួយចំនួន............................................. ៥៥
ការណែនាំអំពីលោកអ៊ិបនូអាល់ជៅហ្ស៊ីចំពោះជនអកតញ្ញូ.......... ៥៨




# ការគោរពប្រតិបត្តិចំពោះមាតាបិតា

## ការគោរពប្រណិបត្តិចំពោះមាតាបិតាគឺមានបញ្ជាក់នៅក្នុងគម្ពីរអាល់គួរអាន

ជាការពិតណាស់វាក្យខ័ណ្ឌរបស់អល់ឡោះជាច្រើនពាក់ព័ន្ធគ្នាជាហូរហែរស្តីពីការអភ័យទោសរបស់ឪពុកម្តាយ ក្រោយការសណ្តោសប្រណីរបស់អល់ឡោះ ហើយការធ្វើអំពើល្អចំពោះមាតាបិតាចាត់ទុកជាផលបុណ្យមហាសាលបន្ទាប់អំពីតំលៃដ៏ឧត្តុង្គឧត្តមនៃជំនឿចំពោះអល់ឡោះ ។

អាស្រ័យដូចនេះចំពោះសិទ្ធិ និងភារកិច្ចធំធេងនោះគឺមានតំលៃដ៏អស្ចារ្យភាពឧត្តុង្គឧត្តម និងគួរអោយអោនលំទោនបំផុត ។ដូចអល់ឡោះមានបន្ទូលជំពូកអាន់នីសាកវាក្យខ័ណ្ឌ៣៦ថា:

(واعبدوا الله ولا تشركوا به شيئا وبالوالدين إحسانا ) سورة النساء36

មានន័យថា: ចូរពួកអ្នកគោរពសក្ការៈអល់ឡោះ ពួកអ្នកកុំប្រព្រឹត្តអំពើស្ទីរិក[១] ចំពោះទ្រង់ក្នុងប្រការណាមួយអោយសោះ ហើយពួកអ្នកត្រូវធ្វើអំពើល្អចំពោះឪពុកម្តាយ ។ស្ទីរិក

- អល់ឡោះបានមានបន្ទូលនៅក្នុងជំពូកអាល់អាន់អាមវាក្យខ័ណ្ឌ១៥១ថា:

(قُلْ تعالَوا أتلُ ما حرم ربكُم عليكُم ألا تشركُوا بِه شيئًا وبِالوالدين إحسانا ) سورة الأنعام151

[១] - អំពើពហុទេពនិយម

មានន័យថា: ឱមូហាំម៉ាត់! ចូរអ្នកមានប្រសាសន៍ចុះថា: សូមពួកអ្នកនាំគ្នាមកអាន នូវអ្វីដែលម្ចាស់ពួកអ្នកបានដាក់បំរាមមកលើពួកអ្នកថា: ពួកអ្នកកុំប្រព្រឹត្តអំពើស្ហ៊ីរិក ចំពោះទ្រង់ក្នុងប្រការណាមួយអោយសោះ ហើយពួកអ្នកត្រូវធ្វើអំពើល្អចំពោះឪពុកម្តាយ ។

ជាការពិតណាស់អល់ឡោះបានបញ្ជានិងផ្តាំដល់មនុស្សជាតិអោយធ្វើអំពើល្អទៅកាន់អ្នកមានគុណទាំងពីរ ។ ទ្រង់មានបន្ទូលនៅក្នុងជំពូកអាល់អាន់កាប៊ូដវាក្យខ័ណ្ឌ៨ថា:

( ووصينا الإنسانَ بِوالديه حسنا وإن جاهداك لتشرِكَ بِى ما لَيس لَكَ بِهِ علم فَـَلا تطعهما ) سورة العنكبود : 8

មានន័យថា: យើងបានប្រើអោយមនុស្សជាតិធ្វើអំពើល្អចំពោះឪពុកម្តាយ តែបើពួកគាត់ទាំងពីរ ព្យាយាមអូសទាញអ្នកឱ្យប្រព្រឹត្តអំពើស្ហ៊ីរិកចំពោះយើងនូវប្រការណាមួយដែលអ្នកមិនដឹងពីបញ្ហានោះទេ ចូរអ្នកកុំប្រតិបត្តិតាមពួកគាត់ទាំងពីរអោយសោះ ។

◆អល់ឡោះបានមានបន្ទូលនៅក្នុងជំពូកអាល់ឡុកម៉ាន វាក្យខ័ណ្ឌ១៤ថា:

( **ووصينا الإنسانَ بِوالديه حملته أُمه** وهنا علَىٰ وهنٍ وفصاله فى عامينِ أَن اشكُر لى ولوالديك إِلَى المَصير ) سورة لقمان:14

មានន័យថា: យើងបានប្រើអោយមនុស្សជាតិធ្វើអំពើល្អចំពោះឪពុកម្តាយរបស់ខ្លួន ដោយសារម្តាយពរពោះលំបាកស្ទួនលើលំបាក បន្ទាប់មកក៏បំបៅកូនរបស់ខ្លួនរយៈពេលពីរឆ្នាំបន្តទៀត ដូចនេះ ចូរពួកអ្នកសំដែងអំណរ



គុណចំពោះយើង( អល់ឡោះ)និង ចំពោះមាតាបិតារបស់ខ្លួន ។ចំពោះយើងតែមួយគត់ដែលជាកន្លែងពួកអ្នកត្រូវវិលទៅរក ។

ជានិច្ចកាលគួរអានបានចង្អុលបង្ហាញចំពោះឋានៈ និងតំលៃរបស់អ្នកមានគុណទាំងពីរ ហើយទ្រង់បានបង្ហាញផ្លូវដ៏ត្រឹមត្រូវដែលចាំបាច់តំរូវអោយមូស្លីមអនុវត្តតាមនូវការទំនាក់ទំនងល្អចំពោះឪពុកម្តាយប្រសិនបើពួកគាត់ទាំងពីរមានវាសនានៅមានជីវិតរហូតដល់ចាស់ជរា ទន់ខ្សោយមែន ដូចអល់ឡោះមានបន្ទូលនៅក្នុងជំពូកអាល់អ៊ីសរ៉ក វាក្យខ័ណ្ឌ២៣-២៤ថា:

( وقَضى ربك أَلا تعبدوا إلا إِياه وبِالوالدينِ إِحسانا إِما يبلُغن عندك الكبر أَحدهما أَوْ كلاَهما فَلاَ تقُل لهمآ أُف ولاَ تنهرهما وقُل لهما قَولاً كَرِيمًا واخفض لَهما جناح الذل من الرحمة وقُل رب ارحمهما كَما ربيانِي صغيرا ) الاسراء : 23-24

មានន័យថា: ម្ចាស់របស់អ្នកបានដាក់បញ្ជាមកលើអ្នកថា: ពួកអ្នកកុំគោរពសក្ការៈអ្វីផ្សេង លើកលែងតែចំពោះទ្រង់មួយគត់ ហើយពួកអ្នកត្រូវធ្វើអំពើល្អចំពោះឪពុក ម្តាយ នៅពេលដែលម្នាក់ក្នុងចំណោមពួកគាត់ទាំងពីរឬពួកគាត់ទាំងពីរចូលដល់វ័យជរា ។ អ្នកកុំពោលពាក្យសំដីទៅកាន់អ្នក ទាំងពីរ សូម្បីតែពាក្យ អ៊ិសអ៊ុះ (ដែលជាពាក្យអសុរស) និងកុំគំហក កំហែងដាក់លោកទាំងពីរអោយសោះ ផ្ទុយទៅវិញ អ្នកត្រូវប្រើពាក្យល្អផ្អែមល្ហែមទៅកាន់លោកមានគុណទាំងពីរ ។អ្នកត្រូវដាក់ខ្លួនដាក់កាយចំពោះលោកទាំងពីរ ហើយអ្នកត្រូវបួងសួងអោយពួកគាត់ថា: ឱអល់ឡោះជាម្ចាស់របស់ខ្ញុំ!

សូមទ្រង់ផ្តល់ក្តីករុណាដល់លោកទាំងពីរផង ដូចដែលពួកគាត់ ទាំងពីរបាន បីបាច់ថែរក្សារូបខ្ញុំតាំងពីកុមារភាពមកម្ល៉េះ ។

## ច្បាំប្រការមិនត្រូវអោយកើតមានចំពោះអ្នកមានគុណទាំងពីរ

**ទី១**-សូមអ្នកកុំស្តីបន្ទោស សំឡក់សំឡឹង ឬជេរតិះដៀលទៅលើពួកគាត់ទាំងពីរអោយសោះដែលធ្វើអោយអាប់អោនកិត្តិយសដល់ពួកគាត់ និងអាចអោយអ្នកដទៃមើលងាយ ផ្ទុយទៅវិញអ្នកត្រូវតាំងចិត្តអំណត់លើបញ្ហាទាំងពួងចំពោះគាត់ទាំងពីរហើយរំពឹងផលបុណ្យពីអល់ឡោះដូចដែលលោកទាំងពីរអត់ធ្មត់ចំពោះការថែរក្សារូបអ្នកកាលនៅវ័យក្មេងហើយអ្នកមិនត្រូវធុញទ្រាន់គ្រប់កិច្ចការទាំងអស់ទោះតូចក្តី ធំក្តី ។

**ទី២**-សូមអ្នកកុំប្រើពាក្យសំដីព្រហើនកោងកាច ឬប្រើពាក្យសំដីអសុរសដាក់លោកមានគុណទាំងពីរអោយសោះ ។

**ទី៣**- អ្នកត្រូវប្រើពាក្យសំដីផ្អែមល្ហែម ទន់ភ្លន់ សុភាពរាបសារទៅកាន់លោកមានគុណទាំងពីរដោយភ្ជាប់នូវការលើកតំកើងពីអ្វីដែលបង្ហាញនូវសីលធម៌និងសុជីវធម៌ ។ ដូចជាការប្រើពាក្យសំដីផ្អែមល្ហែមទៅកាន់លោកទាំងពីរថាៈ ឱលោកឪពុកអ្នកម្តាយជាទីស្រលាញ់របស់ខ្ញុំ!....ជាដើម ។

អ្នកមិនត្រូវហៅឈ្មោះរបស់ពួកគាត់ទាំងពីរដោយចំៗឈ្មោះទេ ហើយក៏មិនត្រូវនិយាយសំលេងខ្លាំងៗនៅចំពោះលោកទាំងពីរនោះដែរ និងមិនត្រូវសំឡក់សំលឹងដាក់ពួកគាត់ជាដាច់ខាត ។ ប៉ុន្តែអ្នកត្រូវមើលទៅកាន់គាត់ទាំងពីរ



ដោយភាពទន់ភ្លន់អោនលំទោន សុភាពរាបសារ ។ អល់ឡោះបានមានបន្ទូលនៅក្នុងជំពូកអាល់អ៊ីសរ៉កវាក្យខ័ណ្ឌ២៤ៈ

**(واخفض لهما جناح الذل من الرحمة وقل رب ارحمهما كما ربياني صغيرا)**

មានន័យថាៈ អ្នកត្រូវដាក់ខ្លួនដាក់កាយចំពោះលោកទាំងពីរ ហើយអ្នកត្រូវបួងសួងអោយពួកគាត់ថាៈឱអល់ឡោះជាម្ចាស់របស់ខ្ញុំ! សូមទ្រង់ផ្តល់ក្តីករុណាដល់លោកទាំងពីរផង ដូចដែលពួកគាត់ទាំងពីរបានបីបាច់ថែរក្សារូបខ្ញុំតាំងពីកុមារភាពមកម្ល៉េះ ។ ។

- លោកអ៊ូរវ៉ាស់បានពោលថាៈ ជាការពិត កាលណាអ្នកមានគុណទាំងពីរក្រោធខឹងអ្នក ចូរអ្នកកុំបើកភ្នែកសំឡក់សំលឹងដាក់ពួកគាត់ទាំងពីរឱ្យសោះ ពីព្រោះ គេតែងសំគាល់ឃើញថា ការក្រោធខឹងរបស់បុគ្គលណាម្នាក់ គឺគេសំឡក់សំលឹងយ៉ាងមុតស្រួចទៅលើមនុស្សដែលខ្លួនខឹងនោះជាក់ជាមិនខាន ។

**ទី៤**- អ្នកត្រូវបួងសួងសុំអល់ឡោះដើម្បីអោយទ្រង់មេត្តាករុណាអាណិតអាសូរដល់ពួកគាត់ទាំងពីរតាមរយៈក្តីករុណាដ៏ធំទូលាយបំផុតរបស់ទ្រង់និងដើម្បីទ្រង់ប្រទានផលបុណ្យដល់អ្នកដោយសារក្តីករុណារបស់លោកទាំងពីរ ។

**ទី៥**-អ្នកត្រូវអោនលំទោន សុភាពរាបសារ ទន់ភ្លន់ចំពោះអ្នកមានគុណទាំងពីរ ហើយអ្នកត្រូវស្តាប់បង្គាប់ពួកគាត់នូវអ្វីដែលពួកគាត់បានប្រើអ្នក បើការប្រើនោះមិននាំទៅដល់ការប្រព្រឹត្តអំពើប្រឆាំងនឹងអល់ឡោះទេ ។

ត្រូវយកចិត្តទុកដាក់ទទួលដោយរីករាយ នៅពេលដែលពួកគាត់ទាំងពីរសំណូមពរអ្នក ។ អ្នកត្រូវថ្នាក់ថ្នម អាណិតអាសូរពួកគាត់ទាំងពីរ ពីព្រោះ

ពួកគាត់ទាំងពីរត្រូវការអ្នកថ្នាក់ថ្នមនៅពេលពួកគាត់ចូលដល់វ័យចាស់ជរាទន់ខ្សោយនោះ។ ប្រសិនបើអ្នកធ្វើព្រងើយកន្តើយ ឬធ្វេសប្រហែសចំពោះការបីបាច់ថែរក្សាពួកគាត់ទាំងពីរតែបន្តិច នោះភាពអន្តរាយនឹងកើតមានជាក់ជាមិនខាន។

ពាក្យដែលបង្គាប់ប្រើអោយប្រព្រឹត្តអំពើល្អទៅកាន់ឪពុកម្តាយនោះ គឺការបង្ហាញជាលក្ខណៈទូទៅ ទោះបីកូនទទួលព្រមឬមិនព្រមក៏ដោយចុះ ពោលគឺមិនអាចប្រឆាំងជំទាស់និងតវ៉ាបាននោះឡើយ។ គម្ពីរអាល់គួរអានពិតជាបានដាក់បញ្ញានូវរាល់ទិសដៅទាំងឡាយគឺអោយប្រព្រឹត្តតែអំពើល្អទាំងអស់ ហើយអល់ឡោះក៏បានផ្តាំផ្ញើអោយមនុស្សជាតិទាំងអស់ធ្វើអំពើល្អចំពោះអ្នកមានគុណទាំងពីរ បើទោះបីពួកគាត់មិនមែនជាអ្នកអ៊ីស្លាមក៏ដោយ។ អល់ឡោះបានមានបន្ទូលនៅក្នុងជំពូកអាល់ឡុកម៉ានវាក្យខ័ណ្ឌ១៥ថាៈ

(وإن جاهداك على أن تشرك بى ما ليس لك به علم فلا تطعهما وصاحبهما فى الدنيا معروفًا ) سورة لقمان : 15

មានន័យថាៈ **តែប្រសិនបើគាត់ទាំងពីរបង្ខិតបង្ខំអ្នកឱ្យធ្វើអំពើស្ទីរិកចំពោះយើងនូវប្រការណាមួយដែលអ្នកមិនបានដឹងទេនោះ អ្នកកុំប្រតិបត្តិតាមលោកទាំងពីរឱ្យសោះ តែត្រូវគោរពពួកគាត់នៅក្នុងលោកីយ៍ដោយសមរម្យ។**



## លក្ខខណ្ឌចំពោះការធ្វើអំពើល្អដល់មាតាបិតា

ចំពោះការធ្វើអំពើល្អចំពោះឪពុកម្តាយមានបីលក្ខខណ្ឌពោលគឺច្បាប់មិនទាន់ចាត់ទុកថាកូនកតញ្ញូទេ បើគេមិនទាន់បានអនុវត្តតាមលក្ខខណ្ឌបីដូចខាងក្រោមនេះ :

**ទី១-**ត្រូវផ្តល់ការអនុគ្រោះចំពោះឪពុកម្តាយជាងខ្លួនឯង ជាងភរិយាខ្លួនជាងកូនៗរបស់ខ្លួន និងជាងអ្នកដទៃទាំងអស់។

**ទី២-** ត្រូវគោរពតាមទាំងស្រុងនូវអ្វីដែលពួកគាត់ទាំងពីរបានបង្គាប់ប្រើនិងហាមឃាត់ ទោះបីប្រការនោះគាប់តាមតំរូវចិត្ត ឬមិនគាប់ចិត្តរបស់ខ្លួនក៏ដោយ អោយតែការបង្គាប់ប្រើនោះមិនមែនជាអំពីប្រឆាំងច្បាប់របស់អល់ឡោះ។

**ទី៣-**គេត្រូវប្រគល់ជូនពួកគាត់ទាំងពីររាល់អ្វីៗដែលអ្នកយល់ថា វាជាវត្ថុដែលលោកទាំងពីរពេញចិត្ត ដោយមិនចាំបាច់ពួកគាត់ស្នើសុំនោះទេ។ ជាមួយនេះដែរ គេត្រូវមានអារម្មណ៏ថាវាមិនទាន់គ្រប់គ្រាន់ និងមិនពេញលេញនៅក្នុងតំលៃនៃសិទ្ធិរបស់ពួកគាត់នោះទេ ទោះបីរូបគេបរិច្ចាគទាំងការរស់នៅ ឬចំណាយទ្រព្យសម្បត្តិរបស់គេយ៉ាងណាក៏ដោយ។

## ឧត្តមភាពចំពោះការគោរពប្រណិប័តន៍មាតាបិតា

ចំពោះការធ្វើអំពើល្អចំពោះឪពុកម្តាយមានឧត្តមភាពនិងផលប្រយោជន៏ធំធេងណាស់ ដូចមានបញ្ជាក់នៅក្នុងភស្តុតាងថា:

១-ជាការពិតណាស់ការធ្វើល្អចំពោះឪពុកម្តាយ គឺស្ថិតក្នុងចំណោមនៃទង្វើដែលអល់ឡោះស្រលាញ់បំផុតដូចមានហាហ្ទីស្ស[២] បានបញ្ជាក់ថា:

عن عبد اللهِ بن مسعود قَالَ سأَلت رسولَ اللهِ صلى الله عليه وسلم: أي الأعمال أحب إلىَ اللهِ؟ قَالَ : ( الصلاةُ على وقْتها، قُلت: ثُم أي؟ قَالَ: بِر الوالدين ،قُلت: ثُم أي؟ قَالَ:(الْجِهاد في سبِيلِ اللهِ)[متفق عليه].

លោកអាប់ឌុលឡោះកូនម៉ាសអ៊ូតបានពោលថា:ខ្ញុំបានសួរណាហ្ពីមូហាំម៉ាត់ថា: តើអំពើអ្វីខ្លះដែលអល់ឡោះស្រលាញ់ជាងគេ?"លោកមានប្រសាសន៏ថា:"គឺសឡាហ៏អោយចំពេលរបស់វា " ខ្ញុំសួរលោកទៀតថា:"តើបន្ទាប់អំពីកិច្ចការនោះគឺអ្វី?"លោកមានប្រសាសន៏ ថា:"ការធ្វើល្អចំពោះឪពុកម្តាយ " ខ្ញុំសួរទៀតថា : " បន្ទាប់មកជាអ្វី?" លោកបានមានប្រសាសន៏ថា:" ការតស៊ូក្នុងផ្លូវរបស់អល់ឡោះ"។

២- ជាការពិតណាស់ការធ្វើអំពើល្អចំពោះឪពុកម្តាយស្ថិតក្នុងចំណោមមូលហេតុដែលនាំអោយបានចូលឋានសួគ៌។ ដូចហាហ្ទីស្សបានបញ្ជាក់ប្រាប់:

عن أَبِي هريرةَ رضي اللهُ عنه قَالَ : سمعت رسولَ اللهِ صلى اللهُ علَيه وسلم يقُولُ : { رغم أَنفه، رغم أَنفه، رغم أَنفه } قيلَ: من يا رسولَ اللهِ؟ قَالَ: { من أَدرك والديه عند الْكبرِ أَحدهما أَو كلَيهما ثُم لَم يدخل الْجنةَ } (رواه مسلم والترمذي)

មានន័យថា: អាបួហ៊ូរ៉ៃរ៉ោះបានពោលថា: ខ្ញុំបានលឺរ៉សូលុលឡោះមានប្រសាសន៏ថា: ថោកទាបណាស់! ថោកទាបណាស់! ថោកទាបណាស់! មានគេសួរលោកថា:ឱរ៉សូលុលឡោះ! តើនរណាទៅ? លោកមានប្រសាសន៏ថា: ( គឺអ្នកដែលមានជីវិតទាន់ឪពុកម្តាយ ឬម្នាក់ក្នុងចំណោមអ្នកទាំងពីរចូលដល់វ័យចាស់ជរា តែរូបគេ(ជាកូន)បែរជាមិនបានចូលឋានសួគ៌(ដោយសារកូនរូបនោះមិនបានធ្វើល្អចំពោះឪពុកម្តាយ ) ។

មានសេចក្តីរាយការណ៏មួយទៀតអំពីមូអាវីយ៉ះកូនយ៉ាហ៊ីម៉ះតាមរយ:ឪពុករបស់ លោកបានពោលថា:ខ្ញុំបានទៅជួបណាហ្ពី[៣] ខ្ញុំបានសំណូមពរលោកក្នុងការចូលរួមតស៊ូក្នុងបុព្វហេតុអល់ឡោះ ខណ:នោះលោកបានសួរខ្ញុំថា:

فَقَالَ: (أَلَك والدان؟ )قُلْت: نعم ، قَالَ : ( فَالْزمهما فَإِن الْجنةَ تحت أَرجلهما ). رواه الطبراني

តើអ្នកមានឪពុកម្តាយដែរឬទេ?"ខ្ញុំក៏បានឆ្លើយថា:"បាទខ្ញុំមាន"។ លោកក៏បានមានប្រសាសន៏ថា:"ចូរអ្នកយកចិត្តទុកដាក់ថែរក្សារចំពោះគាត់ទាំងពីរ ព្រោះថា ឋានសួគ៌នៅខាងក្រោមជើងរបស់អ្នកទាំងពីរ! "

៣- ជាការពិតណាស់ ការធ្វើអំពើល្អជាមូលហេតុមួយនាំអោយមានអាយុវែង និងមានលាភសក្ការ:កាន់តែរីកចំរើន។

២-ហាហ្ទីស្ស គឺរាល់ពាក្យសំដី កាយវិកានិងការឯកភាពរបស់សាហាវីមូហាំម៉ាត់។

៣ -ណាហ្ពី : ព្យាការីមូហាំម៉ាត់។

អំពីលោកសាល់ម៉ានបានពោលថា: ជាការពិតណាស់រ៉ស៊ូលុលឡោះបានមានប្រសាសន៍ថា :

قَالَ النبي صلى الله علَيه وسلم :( لا يرد القَضاءَ إلا الدعاءُ ، ولا يزيد في العمرِ إلا البِر ) رواه الترمذي .

មានន័យថា: ( គ្មានអ្វីអាចរុញច្រានចំពោះការកំណត់របស់អល់ឡោះ ក្រៅពីការបួងសួងសុំអំពីអល់ឡោះឡើយ ហើយក៏គ្មានអ្វីដែលអាចធ្វើអោយអាយុវែងក្រៅពីសាងអំពើល្អនោះ )។

លោកអាណាសក៏បាននិយាយថា: រ៉ស៊ូលុលឡោះមានប្រសាសន៍ថា :

قال:(من سره أنْ يمد له في عمره ويزاد في رزقه فَليبر بِوالديه وليصلْ رحمه) رواه أحمد .

មានន័យថា: ( បុគ្គលណាប្រាថ្នាចង់បានអាយុវែង និងចង់បានលាភសក្ការៈកើនឡើងនោះ គេត្រូវធ្វើល្អចំពោះឪពុកម្តាយនិងផ្សារភ្ជាប់សាច់សារលោហិតរបស់គេ )។

៤- ជាការពិតណាស់ការធ្វើអំពើល្អ ជាមូលហេតុមួយក្នុងចំណោមមូលហេតុដែលអល់ឡោះទទួលយកនូវការប្រតិបត្តិ ហើយត្រូវបានគេលុបចោលនូវអំពើអាក្រក់របស់គេ ។ អល់ឡោះមានបន្ទូលនៅក្នុងជំពូកអាល់អះកាហ្វ វាក្យខ័ណ្ឌ១៥-១៦ថា:

( ووصينا الإنسانَ بِوالديه إحسانا حملته أُمه كُرْها ووضعته كُرْها وحملُه وفصالُه ثَلاثُونَ شهرا حتىَ إذَا بلَغَ أشده وبلَغَ أرْبعين سنةً قَالَ



رب أوْزِعنِى أنْ أشكُر نِعمتك التى أنعمت علَى وعلَى والدى وأنْ أعملَ صالحا ترْضاه وأصلحْ لى فى ذُريتى إنى تبت إلَيك وإنى من المُسلمين. أُولَئك الذين نتقَبلُ عنهمْ أحسن ما عملُوا ونتجاوز عن سيئَاتهمْ فى أصحابِ الجَنة وعد الصدْقِ الذى كَانوا يوعدونَ )

មានន័យថា: ˝យើងបានប្រើមនុស្សជាតិអោយធ្វើអំពើល្អចំពោះឪពុកម្តាយរបស់ខ្លួន ដោយសារម្តាយពរពោះលំបាកស្ទួនលើលំបាក ហើយពេលសំរាលមកក៏លំបាកថែមទៀត។ ទាំងការពរពោះនិងការបំបៅកូនមានរយៈ ពេល៣០ខែ ទំរាំរូបគេរឹងមាំ លុះពេលគេមានអាយុ៤០ឆ្នាំ គេក៏បានបួងសួង សុំពីអល់ឡោះថា: ឱម្ចាស់របស់ខ្ញុំ! សូមទ្រង់ផ្តល់អោយខ្ញុំនូវការចេះថ្លែងអំណរគុណដល់ឧបការៈគុណរបស់ទ្រង់ ដែលទ្រង់បានប្រទានអោយរូបខ្ញុំ និងមាតាបិតារបស់ខ្ញុំ ហើយទ្រង់បានផ្តល់ឱកាស អោយខ្ញុំបានប្រតិបត្តិកិច្ចការល្អៗ ដែលទ្រង់យល់ព្រម ។សូមទ្រង់កែតំរូវរូបខ្ញុំនិងកូនចៅរបស់ខ្ញុំផង ពិតណាស់ រូបខ្ញុំ សូមសារភាពកំហុសចំពោះទ្រង់ ហើយរូបខ្ញុំសូមស្ថិតក្នុងចំណោមអ្នកមូស្លីម។ ជំពូកមនុស្សប្រភេទនេះហើយ ដែលយើងព្រមទទួលយកការសាងកុសលល្អ ហើយយើងមិន យកទោសពួកគេឡើយទុកអោយពួកគេស្ថិតនៅឋានសួគ៌។ អល់ឡោះរក្សាកិច្ចសន្យា ដែលទ្រង់បានសន្យាចំពោះពួកអ្នក។

អំពីកូនរបស់លោកអ៊ូម៉ើរបានពោលថា: បុរសម្នាក់ទៅជួបណាហ្គី ពេលនោះគាត់បានរៀបរាប់ប្រាប់ណាហ្គីថា: ខ្ញុំបានប្រព្រឹត្តបាបកម្មធំ តើខ្ញុំមានវិធីណា

សំរាប់សារភាពកំហុសដែរទេ? ពេលនោះ ណាប៊ីក៏បានសួរបុរសនោះថា:

فقال: ( هلْ لَك من أُم؟) قَالَ: لاَ، قَالَ : ( فَهلْ لَك من خالَة؟ )

قَالَ: نعم، قَالَ:( فَبِرّها) رواه الترمذي

មានន័យថា:តើអ្នកនៅមានម្តាយដែរឬទេ?"បុរសនោះឆ្លើយថា:ខ្ញុំគ្មានទេ។ ណាប៊ីបានសួរទៀតថា:"តើអ្នកនៅមានម្តាយមីងឬទេ?" បុរសឆ្លើយថា:បាទ គឺខ្ញុំមាន។ លោកបានប្រាប់បុរសនោះថា: ចូរអ្នកធ្វើល្អចំពោះម្តាយមីងចុះ ។

៥- ជាការពិតណាស់ការធ្វើអំពើល្អ ជាមូលហេតុដែលអល់ឡោះសណ្តោសប្រណីដល់ខ្ញុំរបស់ទ្រង់។ នៅក្នុងហាហ្ទីស្សមួយបញ្ជាក់ថាអំពីអាប់ឌុលឡោះកូនអាំរូបានពោលថា:ជាការពិតណាស់"រ៉ស៊ូលុលឡោះបានមានប្រសាសន៍ថា:

قال:(رضاَ الرب في رِضا ٱلوالدينِ وسخطَه في سخطهما )رواه الطبراني

មានន័យថា: " ក្តីករុណារបស់អល់ឡោះស្ថិតនៅលើការសណ្តោសប្រណីរបស់ឪពុកម្តាយ ហើយការក្រោធខឹងរបស់ទ្រង់ស្ថិតនៅលើការស្អប់ខ្ពើមរបស់អ្នកមានគុណទាំងពីរ ។

៦- ជាការពិតណាស់ការធ្វើអំពើល្អជាមូលហេតុដែលអល់ឡោះទទួលយកការបួងសួង និងផ្តល់នូវដំណោះស្រាយ ពេលមានការទាល់ច្រកនិងគ្រោះអាសន្នផ្សេងៗ។ ដូចហាហ្ទីស្ស"រ៉ស៊ូលុលឡោះមួយបញ្ជាក់ថា:

عن عبد اللهِ بنِ عمر عن رسولِ اللهِ صلى الله عليه وسلم أنه قَالَ بينما ثَلاَثَةُ نفَرٍ يتمشونَ أخذَهم الْمطَر فَأووا إِلىَ غَارٍ في جبلٍ فَانحطَت على فَم غَارِهم صخرةٌ من الْجبلِ فَانطَبقَت علَيهم فَقَالَ بعضهم لبعضٍ



اُنظُروا أعمالاَ عملْتموها صالحةً لله فَادعوا اللَهَ تعالىَ بِها لَعل اللَهَ يفَرجها عنكُم فَقَالَ أحدهم اَللهم إِنه كَانَ لي والدان شيخان كَبِيران وامرأتي ولي صبِيةٌ صغار أرعى علَيهم فَإِذَا أرِحت علَيهم حلَبت فَبدأْت بِوالدي فَسقَيتهما قَبلَ بنِي وأنه نأى بِي ذَات يومٍ الشجر فَلَم آت حتى أمسيت فَوجدتهما قَد ناما فَحلَبت كَماَ كُنت أحلب فَجِئْت بِالْحلاب فَقُمت عند رءُوسهما أكْره أنْ أوقظَهما من نومهما وأكْره أنْ أسقي الصبِيةَ قَبلَهما والصبِيةُ يتضاغَونَ عند قَدمي فَلَم يزلْ ذَلك دأبِي ودأبهم حتى طَلَع الْفَجر فَإِنْ كُنت تعلَم أني فَعلْت ذَلك ابتغاءَ وجهك فَافْرِج لَنا منها فُرجةً نرى منها السماءَ فَفَرج اللهُ منها فُرجةً فَرأوا منها السماءَ وقَالَ ٱلآخر اَللهم إِنه كَانت لي ابنةُ عم أحببتها كَأَشد ما يحب الرجالُ النساءَ وطَلَبت إِلَيها نفْسها فَأَبت حتى آتيها بِمائَةَ دينارٍ فَتعبت حتى جمعت مائَةَ دينار فَجِئْتها بِها فَلَما وقَعت بين رِجلَيها قَالَت يا عبد اللهِ اتقِ اللهَ ولاَ تفْتحِ الْخاتم إِلا بِحقه فَقُمت عنها فَإِنْ كُنت تعلَم أني فَعلْت ذَلك ابتغاءَ وجهك فَافْرِج لَنا منها فُرجةً فَفَرج لَهم وقَالَ ٱلآخر اَللهم إِني كُنت اَستأجرت أجِيرا بفَرقِ أرز فَلَما قَضى عملَه قَالَ أعطِنِي حقي فَعرضت علَيه فَرقَه فَرغب عنه فَلَم أزِل أزرعه حتى جمعت منه بقَرا ورِعاءَها فَجاءَنِي فَقَالَ اتقِ اللهَ ولاَ تظْلمنِي حقي قُلْت اذْهب إِلىَ تلْك الْبقَرِ ورِعائها فَخذْها فَقَالَ اتقِ اللهَ ولاَ تستهزِئ بِي فَقُلْت إِني لاَ أستهزِئ بِك خذْ ذَلك الْبقَر ورِعاءَها

فَأَخذَه فَذَهب بِه فَإِنْ كُنت تعلَم أني فَعلْت ذَلك ابتغاءَ وجهك فَافْرِج لَنا ما بقي فَفَرَج اللهُ مابقي . (متفق عليه)

មានន័យថាៈ អាប់ឌុលឡោះកូនអ៊ូម៉ើរ ពីរ៉ស៊ូលុលឡោះបានបញ្ជាក់ថាៈមានបុរសបីនាក់កំពុងតែធ្វើដំណើរ ក៏មានភ្លៀងធ្លាក់យ៉ាងខ្លាំង ពួកគេនាំគ្នាទៅជ្រកក្នុងរូងភ្នំមួយ ស្រាប់តែផ្ទាំងថ្មធំមួយ បានរមៀលមកគ្របពីលើមាត់រូងសង្កត់កន្លែងពួកគេតែម្តង។ ខណៈនោះពួកគេបានពិភាក្សាគ្នាថាៈឥឡូវនេះពួកយើងត្រូវពិនិត្យទៅលើអំពើកុសល ដែលពួកយើងបានសាងដោយចិត្តស្មោះសចំពោះអល់ឡោះ។ តាមរយៈអំពើកុសលនោះ ពួកយើងត្រូវបួងសួងសុំពីអល់ឡោះ សង្ឃឹមថាទ្រង់នឹងដកយកថ្មនោះចេញពីពួកយើងវិញមិនខាន។

**បុរសទី១**ក្នុងចំណោមពួកគេចាប់ផ្តើមបួងសួងអល់ឡោះថាៈ ឱអល់ឡោះជាម្ចាស់! ខ្ញុំមានមាតាបិតាចូលវ័យជរាហើយ និងភរិយាព្រមទាំងកូនតូចៗដែលរូបខ្ញុំមានបន្ទុកជាអ្នកថែរក្សាពួកគេ។ ពេលទំនេរខ្ញុំតែងតែទៅបូតទឹកដោះពពែ រួចរៀបចំជូនអ្នកមានគុណទាំងពីរ មុនអោយកូនៗរបស់ខ្ញុំ។ ជាអកុសល នៅថ្ងៃមួយខ្ញុំមានរវល់ទៅឆ្ងាយ ខ្ញុំមិនបានត្រលប់មកផ្ទះវិញដូចសព្វដងទេ រហូតដល់ល្ងាច។លុះពេលខ្ញុំមកដល់ផ្ទះ ពួកគាត់ទាំងពីរបានដេកលក់អស់ទៅហើយ។ខ្ញុំក៏បូតទឹកដោះពពែដូចសព្វមួយដងទុកជូនលោកមានគុណទាំងពីរ ។រួចមកខ្ញុំក៏ឈរស្ងៀមនៅជិតលោកទាំងពីរ មិនហ៊ានដាស់លោកទាំងពីរអោយភ្ញាក់ពីដំណេកឡើយ។ ខ្ញុំក៏មិនបានអោយកូនរបស់ខ្ញុំផឹក



ទឹកដោះនោះមុនលោកមានគុណទាំងពីរដែរ។ កូនៗរបស់ខ្ញុំសំលឹង ភ្លៀកៗមកកាន់ទឹកដោះពពែនៅក្បែរជើងរបស់ខ្ញុំ ដោយសារការស្រេកឃ្លាន។ ពួកយើងស្ថិតក្នុងសភាពបែបនេះ រហូតដល់ពេលព្រឹកមកដល់។ តាមរយៈទង្វើនេះ ទ្រង់ដឹងពីបំណងរបស់ខ្ញុំដែលធ្វើដើម្បីទ្រង់នោះ សូមទ្រង់បើកចន្លោះអោយពួកយើងបានឃើញពន្លឺព្រះអាទិត្យផង( ឃើញមេឃ) ខណៈនោះអល់ឡោះក៏រំកិលផ្ទាំងថ្មបន្តិចអោយគេបានមើលឃើញមេឃ។

**បុរសទី២**ក្នុងចំណោមពួកគេចាប់ផ្តើមបួងសួងអល់ឡោះថាៈ ឱអល់ឡោះជាម្ចាស់!ខ្ញុំមានជីដូនមួយស្រីម្នាក់ដែលខ្ញុំស្រលាញ់នាងខ្លាំងដូចដែលបុរសៗគេស្រលាញ់ស្រីៗដែរ។ ខ្ញុំបានទទួចសុំនាងរួមសង្វាស( មុនរៀបការ)នាងបានប្រកែកដោយដាក់លក្ខខណ្ឌថាទាល់តែខ្ញុំជូនលុយទៅនាង១០០ឌីណា( លុយប្រទេសអារ៉ាប់ជំនាន់ដើម) ។ខ្ញុំចាប់ផ្តើមប្រមូលលុយគ្រប់ចំនួន ១០០ឌីណាយ៉ាងលំបាកបំផុត បន្ទាប់មកខ្ញុំយកលុយនោះទៅអោយនាង។ នៅពេលខ្ញុំចាប់ផ្តើមអង្គុយនៅចន្លោះជើងទាំងពីររបស់នាង ( ចាប់ផ្តើមរួមសង្វាស) នាងនិយាយមកកាន់ខ្ញុំថាៈ ឱអាប់ឌុលឡោះ! ចូរខ្លាចអល់ឡោះ សូមកុំដកយកចិញ្ចៀនមុនដល់ពេលវា( មុនពេលអ្នកមានសិទ្ធដកយកគឺមុនរៀបការសំដៅទៅលើការរួមសង្វាសមុនរៀបការ)ពេលនោះខ្ញុំក៏ស្ទុះចេញពីនាងភ្លាមតាមរយៈទង្វើនេះ ( ទង្វើដែលខ្ញុំស្ទុះចេញពីការធ្លាក់ខ្លួនទៅលើបាបកម្ម) ទ្រង់ដឹងពីបំណងរបស់ខ្ញុំដែលធ្វើដើម្បីទ្រង់នោះ សូមទ្រង់បើកចន្លោះអោយពួកយើងថែមទៀតផង? ខណៈនោះអល់ឡោះក៏រំកិលផ្ទាំងថ្មបន្តិចថែម

ទៀតអោយពួកគេ។

**បុរសទី៣**ក្នុងចំណោមពួកគេចាប់ផ្តើមបួងសួងអល់ឡោះថាៈ ឱអល់ឡោះជាម្ចាស់! ខ្ញុំបានជួលឈ្នួលបំរើម្នាក់ដោយអោយឈ្នួលជាស្រូវ។ លុះពេលគេបំពេញកិច្ចការរបស់គេចប់ គេបានទាមទារឈ្នួលរបស់គេ ខ្ញុំក៏ផ្តល់អោយគេតាមកិច្ចសន្យា តែបុរសនោះបែរជាមិនព្រមទៅវិញ ហើយខ្ញុំក៏យកស្រូវនោះបន្តដាំទៅទៀតរហូតបានផលចំណេញទិញគោមួយក្បាលនិងជួលអ្នកមើលគោនោះម្នាក់ផងដែរ។ ក្រោយមកបុរសនោះក៏មកជួបនឹងខ្ញុំ ហើយបាននិយាយមកកាន់ខ្ញុំថាៈ ចូរអ្នកកោតខ្លាចអល់ឡោះ កុំបំពានមកលើកម្មសិទ្ធិរបស់ខ្ញុំអោយសោះ! ពេលនោះខ្ញុំប្រាប់បុរសនោះថាៈ អ្នកទៅមើលសត្វគោមួយក្បាលនិងអ្នកឃ្វាលវារួចទទួលយកវាចុះ។ បុរសនោះបានតបមកខ្ញុំវិញថាៈ សូមកុំចំអកដាក់ខ្ញុំអោយសោះ?ពេលនោះខ្ញុំប្រាប់ទៅគាត់វិញថាៈ ខ្ញុំមិនចំអកដាក់លោកឡើយចូរយកគោមួយក្បាលនិងអ្នកឃ្វាលវាចុះ បុរសនោះក៏ទទួលយកចេញទៅ។ តាមរយៈទង្វើនេះ ( ទង្វើដែលខ្ញុំធ្វើល្អទៅលើបុរសស៊ីឈ្នួលនោះ) ទ្រង់ដឹងពីបំណងរបស់ខ្ញុំដែលធ្វើដើម្បីទ្រង់នោះ សូមទ្រង់បើកចន្លោះដែលនៅសេសសល់អោយពួកយើងថែមទៀតផង? ខណៈនោះអល់ឡោះក៏រំកិលផ្ទាំងថ្មទាំងអស់ចេញតែម្តង។

៧- ការធ្វើអំពើល្អចំពោះឪពុកម្តាយ ចាត់ទុកជាទង្វើមួយចំបង មុនភៀសខ្លួន (ពីតំបន់អសន្តិសុខទៅតំបន់សន្តិសុខ) និងការតស៊ូដើម្បីមាគ៌ាអល់ឡោះទៅទៀត។ អំពីអាប់ឌុលឡោះកូនអាំរូកូនអាស្វបានពោលថា : មានបុរស



ម្នាក់បានដើរ សំដៅទៅជួបណាហ្ពី រួចនិយាយទៅកាន់លោកថាៈ

فَقَالَ: أُبايِعك على الْهجرة والْجِهاد ؛ أَبتغي ٱلْأجر من اللِهِ ،فَقَالَ صلى اللهُ علَيه وسلم: (فَهلْ من والديك أَحد حي؟) قَالَ: نعم. بلْ كلاَهما. فقال صلى الله عليه وسلم: (فَتبتغي ٱلْأجر من اللِهِ؟). فقال: نعم. قال صلى الله عليه وسلم:(فَارجِع إِلىَ والديك، فَأَحسِن صحبتهما) (مسلم)

មានន័យថាៈ ខ្ញុំសូមសច្ចានឹងលោកថានឹងធ្វើដំណើរបំលាស់ទី និងតស៊ូជាមួយលោកក្នុងបំណងចង់បានផលបុណ្យពីអល់ឡោះម្ចាស់! ពេលនោះរ៉សូលុលឡោះបានសួរបុរសនោះថាៈ តើក្នុងចំណោមឪពុកម្តាយរបស់អ្នក មានអ្នកនៅមានជីវិតដែរទេ?បុរសនោះឆ្លើយថាៈបាទមាន!ពួកគាត់នៅមានជីវិតទាំងពីរនាក់។ រ៉សូលុលឡោះបានសួរបុរសនោះទៀតថាៈ តើអ្នកពិតជាចង់បានផលបុណ្យពីអល់ឡោះមែនឬ? បុរសនោះឆ្លើយថាៈ បាទ! គឺពិតជាចង់បានមែន រ៉សូលុលឡោះបានប្រាប់បុរសនោះថាៈ បើដូច្នេះសូមអ្នកត្រលប់ទៅជួបឪពុកម្តាយរបស់អ្នក ហើយធ្វើអំពើល្អចំពោះអ្នកមានគុណទាំងពីរចុះ។

៨- ជាការពិតណាស់អ្នកត្រូវធ្វើអំពើល្អចំពោះឪពុកម្តាយរបស់អ្នក រូបអ្នកនឹងទទួលបាននូវការសណ្តោសប្រណីអំពីលោកទាំងពីរ ហើយនៅពេលណាពួកគាត់សណ្តោសប្រណីដល់រូបអ្នកហើយនោះ ពួកគាត់នឹងបួងសួងសុំពីអល់ឡោះសំរាប់រូបអ្នក។ ពិតណាស់ការបួងសួងរបស់ឪពុកម្តាយស័ក្តិសិទ្ធិបំផុត (អល់ឡោះទទួលយកភ្លាមៗពីការបួងសួងរបស់ឪពុកម្តាយដល់កូន)។ ដូចណាហ្ពីមានប្រសាសន៍ថាៈ

قَالَ رسولُ اللهِ صلى الله عليه وسلم: ( ثَلَاثُ دعوات مستجابات لا شك فيهن: دعوةُ الْوالد على ولده، ودعوةُ الْمسافر، ودعوةُ الْمظْلومِ) رواه أحمد

**មានន័យថា: ការបួងសួងសុំពីមនុស្សបីក្រុម គឺត្រូវបានអល់ឡោះទទួលយកដោយគ្មានការសង្ស័យអ្វីឡើយនោះគឺ:**

**① ការបួងសួងរបស់ឪពុកម្តាយសំរាប់កូនរបស់ពួកគាត់ ។**

**② ការបួងសួងរបស់អ្នកធ្វើដំណើរ ។**

**③ ការបួងសួងរបស់ជនដែលគេបំពានទៅលើ ។**

ប្រសិនបើអំពើល្អតាមរយៈអ្នកមានគុណទាំងពីរមិនមានភាពឧត្តុង្គឧត្តមបំផុតនោះទេ ក៏គេមិនចាត់ទុកថាការបួងសួងរបស់គាត់ទាំងពីរស័ក្តិសិទ្ធិត្រូវអល់ឡោះទទួលយកភ្លាមនោះដែរ ។ អាចនិយាយបានថាវាសនារបស់អ្នកនឹងមិនជួបប្រទះឬមិនទទួលរងនូវផ្លូវអពមង្គលជារៀងរហូត ។

**៩**-ជាការពិតណាស់ការធ្វើអំពើល្អ វាស្តែងចេញនូវរូបភាពមួយដ៏ល្អប្រពៃនៅក្នុងពូជពង្ស វង្សត្រកូលរបស់អ្នក ហើយអ្នកផងទាំងពួងក៏ធ្វើល្អចំពោះរូបអ្នកផងដែរ ។ ភាពជាក់ស្តែងនៃអំពើល្អដែលកើតចេញពីភាពកតញ្ញូរបស់អ្នកចំពោះឪពុកម្តាយខ្លួននោះ វានឹងបន្តទៅកូនចៅរបស់អ្នក ។អ្នកត្រូវដឹងថាជីវិតរស់នៅគឺជាបំណុលនិងការតបស្នង ។ ទង្វើឪពុកម្តាយរបស់អ្នកដែលអ្នកពេញចិត្ត នោះកូនៗរបស់អ្នកនឹងប្រតិបត្តិវាចំពោះរូបអ្នកវិញមិនខាន ។

១០-ជាការពិតណាស់ការធ្វើអំពើល្អចំពោះឪពុកម្តាយ វាស្តែងចេញនូវភាពនឹងនរហើយគ្មានវិប្បដិសារីជារៀងរហូត ។ឧទាហរណ៍ថា:នៅពេលណាដែល



ឪពុកម្តាយឬម្នាក់ក្នុងចំណោមពួកគាត់បានទទួលមរណភាព ពេលនោះមនុស្សម្នានឹងពេញចិត្តនិងសប្បាយរីករាយចំពោះកូនដែលបានធ្វើល្អទៅលើអ្នកមានគុណទាំងពីររបស់ខ្លួន ។ ប្រសិនបើអល់ឡោះកំណត់លើឪពុកម្តាយឬម្នាក់ក្នុងចំណោមពួកគាត់ទាំងពីរទទួលមរណៈមុនកូន នោះរូបគេពិតជានឹងគ្មានវិប្បដិសារីឬសោកស្តាយអ្វីឡើយ វាខុសពីកូនអកតញ្ញូចំពោះឪពុកម្តាយខ្លួន( គេពិតជាមានវិប្បដិសារីមិនខាន) ។

**១១**-ការបួងសួងសុំពីអល់ឡោះអោយអ្នកមានគុណទាំងពីរ ។ ពិតណាស់អំពើល្អជាលក្ខណៈសម្បត្តិគួរស្ញប់ស្ញែងដែលត្រូវគេសរសើចំពោះបុគ្គលដែលមានលក្ខណៈសម្បត្តិប្រភេទនេះ ។

**១២-** អំពើល្អជាលក្ខណៈសម្បត្តិមួយក្នុងលក្ខណៈសម្បត្តិរបស់បណ្តាណាហ្ពី ។ អល់ឡោះបានមានបន្ទូលអំពីណាហ្ពីយ៉ះយ៉ានៅក្នុងជំពូកម៉ារីយុំវាក្យខ័ណ្ឌ១៤:

(وبرا بِوالديه ولَم يكُن جبارا عصيا ) سورة مريم : 14

**មានន័យថា:គេបានធ្វើអំពើល្អចំពោះឪពុកម្តាយរបស់គេ ហើយគេមិនដែលកោងកាចប្រឆាំងជំទាស់អ្វីឡើយ ។**

អល់ឡោះមានបន្ទូលអំពីណាហ្ពីអ៊ីសានៅក្នុងជំពូកម៉ារីយាំវាក្យខ័ណ្ឌ ៣២ថា:

( وبرا بِوالدتي ولَم يجعلْنِي جبارا شقيا ) سورة مريم : 32

**មានន័យថា: ខ្ញុំតែងតែធ្វើអំពើល្អចំពោះម្តាយរបស់ខ្ញុំ ហើយទ្រង់មិនដែលចាត់ទុករូបខ្ញុំជាអ្នកកោងកាចនិងអពមង្គលនោះឡើយ ។**

អល់ឡោះបានបង្ហាញលក្ខណៈកូនកតញ្ញូចំពោះមាតាបិតារបស់ខ្លួន

នោះគឺណាហ្គីអ៊ីស្មាអេលនៅក្នុងជំពូកអាសសហ្វាត វាក្យខ័ណ្ឌ១០២ថា:

( قَالَ يٰٓأَبَتِ افْعَلْ مَا تُؤْمَرُ سَتَجِدُنِىٓ إِن شَآءَ اللهُ مِنَ الصَّابِرِينَ )

**មានន័យថាៈ ឱឪពុកជាទីស្រលាញ់! សូមលោកឪពុកអនុវត្តតាមអ្វីដែលអល់ឡោះបញ្ជាចុះ បើអល់ឡោះមានបំណង ខ្ញុំនឹងបានស្ថិតក្នុងចំនោមអ្នកអត់ធ្មត់មិនខាន។**

## កិច្ចការដែលអាចជួយជំរុញក្នុងការធ្វើល្អចំពោះឪពុកម្តាយ

មានប្រការមួយចំនួនដែលអាចជួយជនមូស្លីម អោយធ្វើអំពើល្អចំពោះឪពុកម្តាយរបស់ខ្លួន បើគេប្រកាន់យកប្រការទាំងនោះមកអនុវត្ត។ ប្រការទាំងនោះមានដូចជា :

**១- កូន១ត្រូវចេះបង្ហាញអំពីឧត្តមភាពនៃការធ្វើអំពើល្អ និងផលកម្មចំពោះការអកតញ្ញូមកលើឪពុកម្តាយ :**

ការស្វែងយល់ពីផ្លែផ្កានៃអំពើល្អនិងបង្ហាញចេញផលប្រយោជន៏របស់វាគឺស្ថិតនៅក្នុងជំហានដែលជំរុញចិត្តអោយធ្វើល្អ ឬយកវាធ្វើជាគំរូ។ ត្រូវលើកពីផលកម្មនៃអំពើអកតញ្ញូតាធមិចំពោះមាតាបិតា និងចៀសឆ្ងាយរាល់ការរុញច្រានទៅរកប្រការអកតញ្ញូតាដែលទង្វើទាំងនេះវាជួយទៅលើអំពើល្អ។

**២- កូន១ត្រូវបង្ហាញពីឧត្តមភាពរបស់មាតាបិតាអោយមនុស្សទូទៅដឹងៈ**



លោកទាំងពីរគឺជាមូលហេតុមានវត្តមានរូបគេនៅលើលោកិយនេះ។ លោកទាំងពីរពិតជារងការនឿយហត់បំផុតដោយសាររូបកូន។ ម្តាយបានពរពោះកូនរយៈពេល៩ខែនៅក្នុងផ្ទៃរបស់គាត់ ការឈឺចុកចាប់ ខ្លួនប្រាណនឹងទំងន់ផ្ទៃពោះ បន្ទាប់មកបានសំរាលកូនមកដោយភាពឈឺចាប់និងអស់កំលាំងកាយអាចនិយាយបានថាប្រៀបដូចជាជំងឺដ៏កាចសាហាវ និងឈឺចាប់ដែលមិនអាចនរណានឹងដឹងអំពីទំហំនៃការឈឺចាប់របស់ម្តាយបានឡើយមានតែអល់ឡោះប៉ុណ្ណោះដឹង។ បន្ទាប់មកបន្តបំបៅកូនរយៈពេល២ ឆ្នាំទៀត។ ម្តាយសុខចិត្តស្រេកឃ្លានអោយតែកូនបានឆ្អែត សុខចិត្តនៅកំដរកូនមិនហ៊ានដេកដើម្បីអោយកូនគេងលក់ស្កប់ស្កល់ សុខចិត្តនឿយហត់សព្វបែបយ៉ាងក៏ដើម្បីកូនសំរាកនិងបានសប្បាយ។ ម្តាយគឺជាអ្នកស្រលាញ់កូនជាងគេថ្នាក់ថ្នមចិញ្ចឹមបីបាច់ថែរក្សាការពាររូបកូន។ម្តាយហ៊ានលះបង់គ្រប់បែបយ៉ាងសុខចិត្តស្លាប់អោយតែកូនមានជីវិតរស់នៅរហូតសេចក្តីស្លាប់ បើអាចផ្លាស់ប្តូរគ្នាបានម្តាយហ៊ានប្តូរជីវិតជំនួសកូន។ល។

រីឯឪពុកវិញ ជាអ្នកតស៊ូ អត់ធ្មត់ ស្វែងរកលាភីសំរាប់ជីវភាពរស់នៅរបស់គ្រួសារនិងការចំណាយគ្រប់បែបយ៉ាងដើម្បីគ្រួសារ។ ឆ្លងកាត់គ្រប់កាលៈទេសៈទាំងអស់ទោះបីលំបាកវេទនាហាលខ្យល់ហាលភ្លៀងយ៉ាងណាក្តី។ ឪពុកក៏បានជួយរំលែកការងារម្តាយក្នុងការបង្ហាត់បង្រៀននិងអប់រំកូន១របស់គាត់ផងដែរ។**តែជាអកុសល**កូនមួយចំនួន បែរជាមិនអាចសំរបសំរួលខ្លួនក្នុងការបំពេញកាតព្វកិច្ចជាកូនពេញលក្ខណៈចំពោះអ្នកមានគុណដ៏ឧត្តុង្គ

ឧត្តមបាននៅក្នុងន័យនេះកូនត្រូវតែមានមនសិការទទួលខុសត្រូវចំពោះបញ្ហានេះ។ ជាការចាំបាច់ណាស់កូនត្រូវតែធ្វើអំពើល្អចំពោះអ្នកមានគុណទាំងពីរអោយខានតែបាន។

**៣- កូនៗត្រូវដឹងខ្លួនឯងថា កូននឹងក្លាយទៅជាមាតាបិតារបស់គេ**

ឱកូនៗ! តើអ្នកមានអារម្មណ៍យ៉ាងណាដែរនៅថ្ងៃស្អែក (ថ្ងៃខាងមុខ) នៅពេលអ្នកក្លាយទៅជាមនុស្សចាស់ជរាវិញនោះ? សក់របស់អ្នកនឹងក្លាយជាពណ៌ស? អ្នកនឹងក្លាយជាមនុស្សទន់ខ្សោយគ្រប់បែបយ៉ាង? តើមានអារម្មណ៍យ៉ាងណាដែរនៅថ្ងៃខាងមុខ បើអ្នកជួបប្រទះទង្វើអាក្រក់អំពីសំណាក់កូនៗរបស់អ្នកមកលើរូបអ្នកនោះ?

**៤-កូនៗត្រូវចេះសំលឹងមើលគំរូអ្នកដែលមានកតញ្ញូចំពោះមាតាបិតារបស់គេ**

អ្វីដែលអ្នកមានគុណទាំងពីរគួរមាន គឺឱកាសសំរាកកាយនិងការស្ងប់ចិត្ត។ ទាំងនេះបានមកពីការយកចិត្តទុកដាក់ និងទទួលខុសត្រូវខ្ពស់របស់កូនៗក្នុងការធ្វើអំពើល្អចំពោះអ្នកទាំងពីរ។

**៥- កូនៗត្រូវចេះរំលឹកដល់គុណសម្បត្តិរបស់លោកទាំងពីរ ក្នុងពេលលោកទាំងពីរនៅមានជីវិតនិងក្រោយមរណភាព។**

មានឪពុកម្តាយឬម្នាក់ក្នុងចំណោមអ្នកទាំងពីរ ចាត់ទុកជាគុណសម្បត្តិមានតំលៃមួយដែលមិនអាចកាត់ថ្លៃបានឡើយ។ ដូច្នេះក្នុងនាមអ្នកជាកូនត្រូវឆ្លៀតយកឱកាសដែលកំរនេះ សំរាប់តបស្នងសងគុណដល់ពួកគាត់ទាំងពីរ និងត្រូវធ្វើអ្វីៗដើម្បីអោយលោកទាំងពីរបានសប្បាយចិត្តមុនដល់ថ្ងៃនៃ



ក្តីកង្វល់បំផុត ពោលគឺដោយការបាត់បង់លោកទាំងពីរ ដែលអ្នកនឹងមិនបានជួបនិងឃើញអ្នកទាំងពីរជារៀងរហូត។

**៦-កូនៗត្រូវចេះរំលឹកពីកុសលផលបុណ្យ ឋានៈដោយសាការ ធ្វើល្អចំពោះមាតាបិតាៈ**

ឪពុកម្តាយចាត់ទុកថាជាទ្វារពីរក្នុងចំណោមទ្វារឋានសួគ៌ ខណៈដែលអ្នកធ្វើល្អចំពោះលោកទាំងពីរ ហើយជាទ្វារឋាននរក ខណៈដែលអ្នកធ្វើអំពើអកតញ្ញូចំពោះលោកទាំងពីរផងដែរ។ ណាហ្ពីមានប្រសាសន៍ថាៈ

(الْوالد أوسطُ أبوابِ الْجنة ، فَإنْ شئْت فَأَضع ذَلك الْبابَ أو احفَظْه)

رواه الترمذي وصححه الألباني .

មានន័យថាៈ ឪពុកម្តាយគឺស្ថិតនៅកណ្តាលនៃទ្វារឋានសួគ៌ ដូចនេះបើអ្នកមានបំនង(ចង់បានទ្វារឋានសួគ៌) សូមដាក់ទ្វារឬរក្សាទ្វារនោះទុកចុះ។

**៧-បង្កអោយមានភាពរីករាយរបស់មាតាបិតាតាមរយៈអំពើល្អរបស់កូន និងបណ្តាលអោយសោកសង្រេងរបស់អ្នកមានគុណទាំងពីរដោយអំពើអកតញ្ញូរបស់កូនៈ**

ពេលកូនៗសំគាល់ឃើញពីបរិយាកាសមិនរីករាយរបស់មាតាបិតា ចូរប្រញាប់សាងកុសលចំពោះពួកគាត់ភ្លាម និងមិនត្រូវបង្កភាពអកតញ្ញូចំពោះពួកគាត់ឡើយ។

**៨- កូនៗត្រូវបួងសួងសុំពីអល់ឡោះអោយទ្រង់ជួយរូបគេក្នុងការធ្វើអំពើល្អចំពោះមាតាបិតារបស់ខ្លួន។**

គ្មានប្រការអ្វីមួយដែលនាំលាភសក្ការៈដូចការបួងសួងសុំឡើយ និងគ្មានការរុញច្រានអំពើអាក្រក់អោយឆ្ងាយដូចការបួងសួងសុំដែរ ។ ជាការពិតណាស់មនុស្សល្អត្រឹមត្រូវ តែងតែយកចិត្តទុកដាក់បំផុតក្នុងការសាងអំពើល្អគ្រប់បែបយ៉ាងពិសេសការធ្វើអំពើល្អចំពោះមាតាបិតារបស់ខ្លួន គឺត្រូវធ្វើយ៉ាងណាអោយឪពុកម្តាយរបស់ខ្លួនពេញចិត្តចំពោះទង្វើរបស់ខ្លួន ។

**៩- កូនៗទទួលផលពីភាពប្រពៃរបស់ឪពុកម្តាយ**

មនុស្សជាតិត្រូវដឹងថា: ភាពប្រពៃរបស់មាតាបិតានាំអោយកូនៗមានសុភមង្គល និងជាហេតុដែលនាំអោយកូនៗធ្វើអំពើល្អតបស្នងពួកគាត់វិញ ផ្ទុយទៅវិញ ការអសីលធមិរបស់មាតាបិតានាំអោយកូនៗជួបអពមង្គល និងជាហេតុដែលនាំអោយកូនៗសាងបាបកម្មតបស្នងទៅលើពួកគាត់វិញ ។

**១០- កូនៗត្រូវប្រកាន់ជំហរយុត្តិធមិរវាងភរិយានិងមាតាបិតារបស់ខ្លួន**

កូនៗត្រូវផ្តល់និងគោរពសិទ្ធិអោយបានត្រឹមត្រូវ ត្រូវចេះថ្លឹងថ្លែងរវាងតួនាទីមាតាបិតានិងតួនាទីប្រពន្ធរបស់ខ្លួនដោយបន្ថែមទៅជាមួយនូវការធ្វើល្អទាំងការផ្គត់ផ្គង់សំភារៈនិងទាំងខ្លឹមសារចំពោះមាតាបិតារបស់ខ្លួនក្រោយពីរូបគេបានរៀបអាពាហ៍ពិពាហ៍រួច ។



# ការធ្វើល្អចំពោះមាតាបិតា

អំពីអាហ៊្ពីហ៊ូរ៉ៃរ៉ោះបានបញ្ជាក់ថា: មានបុរសម្នាក់បានចូលសំដែងការគួរសមចំពោះណាហ្ពីរួចសួរលោកថា:

فَقَالَ يا رسولَ اللهِ من أحق الناسِ بِحسنِ صحابتي قَالَ أُمك قَالَ ثُم من؟ قَالَ أُمك، قَالَ ثُم من ؟ قَالَ أُمك قَالَ ثُم من قَالَ أَبوك) البخاري.

មានន័យថា: ឱរ៉ស៊ូលុលឡោះ! តើ មនុស្សណាខ្លះដែលខ្ញុំត្រូវធ្វើល្អចំពោះនោះ? លោកបានឆ្លើយថា: (គឺម្តាយរបស់អ្នក) បុរសនោះសួរទៀតថា: បន្ទាប់មកនរណាទៀត? លោកបានឆ្លើយថា:(គឺម្តាយរបស់អ្នក)បុរសនោះសួរបន្តទៀតថា:បន្ទាប់មកអ្នកណា?លោកបានឆ្លើយថា:(គឺម្តាយរបស់អ្នក) បុរសនោះសួរថែមទៀតថា: ចុះបន្ទាប់មកអ្នកណាទៀត? លោកឆ្លើយថា: (គឺឪពុករបស់អ្នក) ។

◆ ណាហ្ពីបានមានប្រសាសន៍ថា:

أن رسولَ الله صلى الله عليه وسلم قَالَ :( إن الله يوصيكُم بِأُمهاتكُم ثَلَاثًا ، إن الله يوصيكُم بِآبائكُم ، إن الله يوصيكُم بِالْأَقْربِ فَالْأَقْربِ )

رواه ابن ماجه صححه الألباني

មានន័យថា:អល់ឡោះបានដាស់តឿនមនុស្សលោកអោយធ្វើល្អចំពោះម្តាយរបស់ខ្លួនចំនួនបីដង(ដាស់តឿនដដែលចំនួនបីដង)ហើយអល់ឡោះបានដាស់តឿនមនុស្សលោកអោយធ្វើល្អចំពោះឪពុករបស់ខ្លួនចំនួនមួយដង(ដាស់តឿនចំនួន១ដង)និងអល់ឡោះបានដាស់តឿនមនុស្សជាតិអោយធ្វើអំពើល្អចំពោះ

សាច់សាលោហិតដែលជិតជាបន្តបន្ទាប់រហូតដល់សាច់ញាតិឆ្ងាយ ។

ហាហ្ទីស្សទាំងពីរខាងលើបង្ហាញពីឧត្តមភាពរបស់ម្តាយ និងអ្វីដែលគាត់ត្រូវបានទទួលពីអំពើល្អ ទាំងភាពស្និទ្ធស្នាល ការយកអាសារ និងការគោរពប្រណិប័តន៍។ ពិតណាស់ណាហ្ពីបានរំលឹកពីមាតាចំនួនបីដង ក្នុងពេលរំលឹកពីបិតាតែមួយដង ដែលជាលទ្ធផលពីការប្រឹងប្រែងនិងការនឿយហត់របស់ម្តាយដោយឡែកបិតាមានចំនុចពិសេសលើសមាតាមួយគឺការផ្គត់ផ្គង់ និងរ៉ាប់រងរបស់គាត់ ។

**កូនលោកហ្ពាត់តាលបានពោលថា :** ជាការពិតម្តាយមានភាពចំបងជាងឪពុកត្រង់បីចំណុចគឺ :

-ការលំបាកវេទនាក្នុងពេលពរពោះ ។

-ការលំបាកនិងឈឺចុកចាប់ក្នុងពេលសំរាល ។

-ការលំបាកវេទនាក្នុងកំឡុងនៅបៅ ។

មូលហេតុដែលលើកតំកើងម្តាយជាងឪពុកគឺពិតជាត្រឹមត្រូវបំផុតព្រោះម្តាយត្រូវការជាចាំបាច់នូវអ្នកជួយគ្រប់គ្រងថ្នាក់ថ្នម និងធ្វើល្អចំពោះរូបគាត់ព្រោះជាធម្មតាគាត់មានភាពទន់ខ្សោយផ្នែករាងកាយគ្មានលទ្ធភាពប្រកបការងារបានគ្រប់យ៉ាងនោះទេ។ តើមាននរណាទៀតដែលត្រូវធ្វើល្អ ចំពោះម្តាយក្រៅអំពីកូននោះ?! ហើយតើនរណាដែលត្រូវបំរើ និងស្មោះត្រង់ចំពោះម្តាយក្រៅអំពីកូននោះ?!



## ដូចម្តេចដែលហៅថាធ្វើអំពើល្អចំពោះមាតាបិតា?

ឱបងប្អូនជាទីស្រលាញ់! អ្នកត្រូវដឹងថា: ការធ្វើល្អចំពោះឪពុកម្តាយនូវរាល់កិច្ចការណាដែលធ្វើអោយគាត់ទាំងពីរយល់ព្រម និងពេញចិត្តប្រកបដោយភាពសប្បាយរីករាយដែលវាមិនលាយឡំនូវអំពើល្មើសចំពោះអល់ឡោះទេ។ កូនកតញ្ញូចំពោះអ្នកមានគុណគឺត្រូវចាត់ទុកខ្លួនដូចជាខ្ញុំបំរើលោកទាំងពីរត្រូវស្តាប់តាមដំបូន្មានរបស់អ្នកទាំងពីរកុំមានការខ្ជិលច្រអូសការធុញទ្រាន់ការរារែកនិងការយឺតយ៉ាវពីអ្វីដែលធ្វើអោយលោកទាំងពីរមានក្តីសង្ឃឹម និងការរីករាយអោយសោះ ព្រោះសិទ្ធិរបស់អ្នកមានគុណទាំងពីរមិនត្រូវបានគេបដិសេធឡើយ ផ្ទុយទៅវិញគេត្រូវតែបំពេញ។ ជនមូស្លីមគ្រប់រូបត្រូវបានច្បាប់ទាមទារអោយធ្វើល្អចំពោះឪពុកម្តាយរបស់ខ្លួន ទាំងពេលនៅរស់និងក្រោយពេលស្លាប់។

## ការគោរពប្រតិបត្តិលោកទាំងពីរពេលគាត់នៅមានជីវិត

ចំនុចនេះមានដូចតទៅ :

១-ត្រូវគោរពប្រណិប័តន៍អ្នកមានគុណទាំងពីរ និងត្រូវចៀសវាងអោយឆ្ងាយអំពីការប្រឆាំងតវ៉ាចំពោះពួកគាត់។ ការគោរពប្រណិប័តន៍អ្នកទាំងពីរត្រូវធ្វើមុនអ្វីទាំងអស់ បើការប្រើរបស់លោកទាំងពីរមិននាំដល់ការប្រព្រឹត្តអំពើខុសឆ្គងចំពោះអល់ឡោះនិងរ៉ស៊ូលរបស់ទ្រង់ទេនោះ។

២-ត្រូវធ្វើល្អចំពោះអ្នកទាំងពីរទាំងពាក្យសំដីនិងកាយវិការ ។

៣-ត្រូវបួងសួងសុំក្តីមេត្តាពីអល់ឡោះអោយពួកគាត់ទាំងពីរ ដែលភាគច្រើន

គួរបួងសួងសុំការសណ្តោសប្រណីដល់រូបគាត់ទាំងពីរអោយបានច្រើន ។
រ៉ស៊ូលុលឡោះមានប្រសាសន៏ថាៈ

قال صلى الله عليه وسلم : (إن الرجلَ لَترفَع درجته في الْجنة فَيقُولُ: يا رب أنى لي هذَا ؟ فَيقَالُ : بِاستغفَارِ ولَدك لَك ) رواه أحمد .

**មានន័យថាៈបុរសម្នាក់ត្រូវបានគេលើកតំកើងឋានៈអោយគាត់នៅក្នុងឋានសួគ៌ ។ ខណៈនោះបុរសនោះសួរថាៈ" ឱអល់ឡោះជាម្ចាស់របស់ខ្ញុំ! តើខ្ញុំបានបែបនេះមកពីអ្វី?" ។ ពេលនោះមានគេប្រាប់គាត់ថា :" អ្នកទទួលបានបែបនេះគឺដោយសារការសុំអភ័យទោសរបស់កូនអ្នកអោយអ្នក " ។**

**៤**-មិនត្រូវរារាំង ប្រើពាក្យទ្រគោះបោះបោក ឬគំហកកំហែងដាក់ឪពុក ម្តាយឡើយ ។

**៥**-ត្រូវធ្វើប្រការណាដែលធ្វើអោយលោកទាំងពីររីករាយសប្បាយចិត្តដោយមិនចាំបាច់លោកទាំងពីរប្រើនោះទេ ។

**៦**-មិនត្រូវនិយាយកាត់សំដីលោកទាំងពីរជាដាច់ខាត ផ្ទុយទៅវិញត្រូវស្តាប់ពាក្យសំដីរបស់ពួកគាត់ ។

**៧**-ត្រូវនិយាយផ្អែមល្ហែម ទន់ភ្លន់ទៅកាន់លោកទាំងពីរ ។

**៨**- មិនត្រូវមានភាពអំនួតទៅលើលោកទាំងពីរជាដាច់ខាត ។

**៩**-ត្រូវប្រើទឹកមុខរីករាយ រាក់ទាក់ ត្រូវចាប់ផ្តើមសាឡាម( ធ្វើបដិសណ្ឋារកិច្ច) ថើបដៃ និងក្បាលរបស់លោកទាំងពីរ ត្រូវសំរួលកន្លែងអង្គុយអោយទូលាយសំរាប់លោកទាំងពីរ ត្រូវដើរពីមុខលោកពេលយប់ ដើម្បីការពារ



លោកនិងត្រូវដើរពីក្រោយលោកពេលថ្ងៃ ក្នុងន័យគោរព និងលើកតំកើងចំពោះលោកទាំងពីរ ។

**១០**- មិនត្រូវឈរពាំងមុខឪពុកម្តាយ ព្រោះវាបង្ហាញពីការខ្វះសុជីវធម៌ដូចគ្នាដែរការសណ្តូកជើង ការលើកជើងចំពោះមុខលោកមានគុណទាំងពីរការគ្រហែម និងការដេកសន្ធឹងពីមុខឪពុកម្តាយក៏ជាប្រការមិនគប្បីដែរ ។

**១១**- ត្រូវជួយកិច្ចការផ្សេងៗរបស់លោកទាំងពីរ ។មិនជាការគួរគប្បីឡើយបើកូនឃើញឪពុកម្តាយយួរឬកាន់អ្វីមួយ ហើយគេបែរជាមិនជួយនោះ! ដូចគ្នាដែរ បើកូនស្រីបានឃើញម្តាយរបស់ខ្លួនដែលម្តាយត្រូវការអោយនាងជួយតែនាងបែរទៅជាធ្វើព្រងើយមិនសហការនោះ ។

**១២**-ត្រូវឆ្លើយតបភ្លាម កាលណាលឺសំលេងឪពុកម្តាយហៅ ។

**១៣**-ត្រូវថែរក្សាការពារកិត្តិយស ភាពថ្លៃថ្នូរ កេរ្តិ៍ឈ្មោះ និងទ្រព្យសម្បត្តិរបស់លោកមានគុណទាំងពីរ ។

**១៤**- មិនត្រូវរំខាននិងមិនបង្កភាពល្អក់កករដល់លោកទាំងពីរឡើយ ។

**១៥**-ត្រូវចេះពិភាក្សាការងារជាមួយអ្នកមានគុណទាំងពីរ និងត្រូវផ្តល់អាទិភាពដល់គំនិតរបស់លោកទាំងពីរ ។

**១៦**- មិនត្រូវបន្ទុះបង្អាប់លោកទាំងពីរឡើយ នៅពេលលោកទាំងពីរធ្វើអ្វីមួយមិនត្រូវតាមចិត្តរបស់អ្នក ។

## ការគោរពប្រណិប័តន៍លោកទាំងពីរក្រោយមរណភាព

ត្រូវដឹងថាការធ្វើអំពើល្អចំពោះអ្នកមានគុណទាំងពីរ គឺមិនត្រឹមតែពេលលោកទាំងពីរនៅរស់ប៉ុណ្ណោះទេ ផ្ទុយទៅវិញអំពើនេះត្រូវធ្វើជារៀងរហូត ទោះជាក្រោយពេលលោកទាំងពីរបានទទួលមរណភាពហើយក៏ដោយ ។ ចំពោះអ្នកដែលមានចេតនាល្អក្នុងការធ្វើអំពើល្អចំពោះអ្នមានគុណទាំងពីរក្នុងពេលលោកនៅមានជីវិត គេនឹងមានឱកាសនៅពេលខាងមុខទៀត ដើម្បីគេទទួលបានផលបុណ្យជាច្រើនបន្តទៀត ។

មធ្យោបាយសំរាប់ធ្វើល្អចំពោះឪពុកម្តាយក្រោយពេលដែលពួកគាត់បានស្លាប់ហើយនោះមានច្រើនអនេក ដូចជាមានហាហ្ទីស្សបញ្ជាក់ដូចខាងក្រោមថា :

**عن أبِي أُسيد الساعدي رضي اللهُ عنه أنه قَالَ: بينما نحن جلُوسٍ عند رسولِ اللهِ صلى اللهُ علَيه وسلم إِذْ جاَءَ رجلٌ من بنِي سلَمةَ فَقَالَ:يارسولَ اللهِ،هلْ بقي من بِر أبواي شيءٌ أبِرهما بِه بعد موتهما؟ قَالَ:(نعم،الصلاَةُ علَيهما،والاستغفَار لَهما،وإِنفَاذُ عهدهما بعدهما ،وصلَةُ الرحمِ التي لاَ توصلُ إلا بِهما، وإِكْرام صديقهما)**

**رواه أحمد وأبو داود**

មានន័យថា: អំពីអ៊ូសៃយិតអាល់អាសាអ៊ីឌីបាននិយាយថា: នៅថ្ងៃមួយពួកយើងបានអង្គុយនៅក្បែររ៉ស៊ូលុលឡោះ ស្រាប់តែមានបុរសម្នាក់អំពីត្រកូលសាឡាម៉ះបានពោលទៅកាន់រ៉ស៊ូលុលឡោះថា: ឱរ៉សូលុលឡោះ! តើមាន



អំពើអ្វីដែលខ្ញុំត្រូវអាចធ្វើអោយឪពុកម្តាយរបស់ខ្ញុំ បន្ទាប់អំពីលោកទាំងពីរបានទទួលមរណភាពដែរឬទេ?លោកបានមានប្រសាសន៏ថា :(ពិតជាមានគឺអ្នកត្រូវបួងសួងសុំពីអល់ឡោះអោយលោកទាំងពីរ និងសុំពីទ្រង់នូវការសណ្តោសប្រណីដល់ពួកគាត់ទាំងពីរ ត្រូវបំពេញការសន្យាដែលពួកគាត់ធ្លាប់បានសន្យាត្រូវផ្សារភ្ជាប់សាច់សាលោហិតរបស់ពួកគាត់ទាំងពីរ និងត្រូវគោរពរាប់អានមិត្តភក្តិរបស់ពួកគាត់ទាំងពីរ) ។

◆ អំពីអាប់ឌុលឡោះកូនអាំរូ ពិតណាស់មានបុរសម្នាក់អំពីអ្នកមកពីជនបទដែលបានជួបគាត់នៅតាមផ្លូវក្រុងម៉ាក្កះ ។អាប់ឌុលឡោះបានធ្វើបដិសណ្ឋារកិច្ច(សាឡាម) ហើយបានអោយបុរសនោះឡើងជិះជំនិះរបស់គាត់ដែលកំពុងជិះ រួចលោកបានអោយឆ្នួតក្បាលដែលគាត់កំពុងជួតនោះទៀត ។ កូនលោកឪណើរបាននិយាយថា: ពួកយើងនាំគ្នានិយាយទៅកាន់អាប់ឌុលឡោះថា: សូមអល់ឡោះជំរះសំអាតរូបអ្នក! ពួកគេនេះជាពួកជនបទទេពួកគេនេះមិនសូវទំនាក់ទំនងល្អប៉ុន្មានទេ! ។ ពេលនោះអាប់ឌុលឡោះបានឆ្លើយតបថា: ពិតណាស់ឪពុករបស់បុរសនេះគឺជាមិត្តភក្តិរបស់អ៊ូម៉ើរកូនខត្តប ហើយខ្ញុំបានលឺរ៉ស៊ូលុលឡោះបានមានប្រសាសន៏ថា:

(إِن أَبر الْبِر صلَةُ الرجلِ أَهلَ ود أَبِيه) رواه مسلم .

មានន័យថា: ការធ្វើល្អដែលអស្ចារ្យបំផុតនោះ គឺការភ្ជាប់សាច់សាលោហិតរបស់បុគ្គលម្នាក់នឹងក្រុមគ្រួសារណាមួយដែលជាទីស្រលាញ់របស់ឪពុកខ្លួន ។

ក្នុងចំណោមកិច្ចការដែលត្រូវធ្វើល្អចំពោះលោកទាំងពីរក្រោយពេលគាត់ទទួលមរណភាពដែរនោះគឺការបរិច្ចាគទ្រព្យសម្បត្តិ (សទ៊ើកោះជើរីយ៉ាស់) ។

◆ អំពីលោកស្រីអាអ៊ីស្ហះបានពោលថា:

أن رجلاً قَالَ للنبِي صلى الله عليه وسلم : ( إن أُمي افْتُلِتَت نفْسها وأظُنها لَو تكَلمت تصدقَت ، فَهلْ لَها أجر إنْ تصدقْت عنها ؟ قَالَ صلى الله علَيه وسلم : نعم ) متفق عليه .

មានន័យថា: មានបុរសម្នាក់បាននិយាយទៅកាន់ណាហ្ពីថា:ពិតណាស់ម្តាយរបស់ខ្ញុំគាត់មានសភាពវិលវល់(ជិតដល់សង្ខា) ខ្ញុំគិតថាបើគាត់និយាយរួចច្បាស់ជាគាត់ធ្វើការបរិច្ចាគមិនខាន ។តើផលបុណ្យនឹងទៅដល់គាត់ទេ បើខ្ញុំបរិច្ចាគអោយគាត់នោះ? ណាហ្ពីឆ្លើយថា:(គឺពិតជាបានដល់) ។

◆ អំពីកូនអ៊ីបនូអាហ្ពាសបាននិយាយថាជាការពិតណាស់សាអាត់កូនអ៊ុហ្ពែឌុះបានរៀបរាប់ប្រាប់ណាហ្ពីថា:

إن أُمي ماتت وعلَيها نذْر فَقَالَ صلى اللهُ علَيه وسلم : (اقْضِ عنها) متفق عليه .

មានន័យថា: ពិតណាស់ម្តាយរបស់ខ្ញុំបានទទួលមរណភាពហើយ តែគាត់នៅជំពាក់ការសច្ចាបន់ស្រន់មិនទាន់បានបំពេញនៅឡើយ ។ ខណៈនោះណាហ្ពីមានប្រសាសន៍ថា: (ចូរអ្នកបំពេញវាជំនួសគាត់ទៅចុះ) ។



**ប្រវត្តិរឿងនៃការគោរពប្រតិបត្តិចំពោះមាតាបិតានៃមនុស្សជំនាន់មុនៗ**

មិត្តអ្នកអានជាទីស្រលាញ់! អ្វីៗដែលយើងបរិយាយកន្លងមកគឺជារូបភាពបង្ហាញពីរបៀបរស់នៅរបស់អ្នកជំនាន់មុនៗដែលត្រឹមត្រូវនោះ! ។ តែបច្ចុប្បន្នភាពវិញ ជាអកុសលខ្លាំងណាស់ ដែលបុគ្គលមួយចំនួនបាននិងកំពុងធ្វើអោយមាតាបិតារបស់គេហូរទឹកភ្នែក ទុក្ខព្រួយគ្មានថ្ងៃល្ងៃ ដេកមិនភ្នែត បង្កក្តីបារម្ភគ្មានលោះពេល និងធ្វើអោយលោកអ្នកមានគុណទាំងពីរស៊ូទ្រាំបៀមទុក្ខសោកនិងគំលាតឆ្ងាយពីសង្គម ធ្វើអោយបាត់បង់រសជាតិជីវិតរបស់លោកអ្នកមានគុណទាំងពីរ! ។

កូនអកតញ្ញូ! អ្នកត្រូវតែបែរមកធ្វើល្អចំពោះមាតាបិតារបស់ខ្លួនជាបន្ទាន់ ព្រោះរបៀបរស់នៅរបស់អ្នកជំនាន់មុនៗដែលត្រឹមត្រូវ គឺគេធ្វើល្អចំពោះមាតាបិតារបស់គេ ។ ជំហរនៃទង្វើល្អចំពោះឪពុកម្តាយពួកគេ គឺជាកត្តាសំខាន់បំផុតសំរាប់គេ ។

យើងលើកមកបង្ហាញ ពីរបៀបរស់នៅរបស់អ្នកជំនាន់មុនៗដែលត្រឹមត្រូវនោះ គឺក្នុងគោលបំណងជំរុញចិត្តគំនិតរបស់យើងទាំងអស់គ្នាឈោងចាប់យកអំពើល្អ និងជំរុញច្រានយើងទាំងអស់គ្នាអោយរកទង្វើសមស្របនិងការធ្វើល្អចំពោះមាតាបិតា ។

**រឿងពិតទាំងនោះមានដូចតទៅ:**

១-អាប់ឌុលឡោះកូនអ៊ូម៉ើរបានឃើញបុរសម្នាក់បានដាក់ម្តាយរបស់ខ្លួននៅលើស្មាខណៈពេលដែលបុរសនោះកំពុងដើរតវ៉ាហ្វជុំវិញកាក់ហ្ពះ ។

បុរសនោះបាននិយាយមកកាន់អាប់ឌុលឡោះថា: ឱអ៊ិបនូអ៊ូម៉ើរ! តើអ្នកឃើញខ្ញុំយកចិត្តទុកដាក់លើកតំកើងចំពោះគាត់ដែរឬទេ?" ។

អ៊ិបនូអ៊ូម៉ើរឆ្លើយថា: " នេះមិនមែនជាការងារធំធេងនៅក្នុងការងារកតញ្ញូនោះទេ តែយ៉ាងណាក៏ដោយ អ្នកពិតជាបានសាងកុសលល្អ។ អល់ឡោះពិតជាតបស្នងសងដល់រូបអ្នកវិញយ៉ាងច្រើនចំពោះកិច្ចការដ៏តិចតួចនេះ! ។

*(ដកស្រង់ពីសៀវភៅអាល់កាហ្គីអៀវរបស់អាស់ហ្សៃហ៊ុហ្គី)* ។

**២-** លោកអាលីកូនអាល់ហ៊ូសេន ហ៊ូសេនកូនអាលី អាលីកូនអាហ្គូតល់ឡិប។ លោកបានធ្វើអំពើល្អយ៉ាងច្រើនចំពោះម្តាយរបស់ខ្លួន រហូតមានគេនិយាយកោតសរសើរគាត់ថា: អ្នកគឺជាកូនកតញ្ញូបំផុតចំពោះអ្នកមានគុណ! ពួកយើងមិនដែលសង្កេតឃើញថាអ្នកធ្វេសប្រហែសរឿងម្តាយរបស់អ្នកឡើយ។ លោកបានប្រាប់ថា: "បានជាខ្ញុំធ្វើបែបនេះ ដោយសារខ្ញុំបារម្ភថា ដៃរបស់ខ្ញុំលូកទៅយករបស់អ្វីមួយ( អោយម្តាយ) ឃើតជាងការសំលឹងរបស់ម្តាយទៅរបស់នោះ ដែលជាហេតុធ្វើអោយខ្លួនខ្ញុំនេះក្លាយជាកូនអកតញ្ញូ!!! ។

*(ដកស្រង់ពីសៀវភៅអ៊ុយ៉ូនអាល់អិខហ្គើររបស់អិបនូគូឡៃហ្គះ)*

**៣-** ជាការពិតណាស់អាហ្គីហ៊ូរ៉ៃរ៉ោះ នៅពេលដែលគាត់ត្រូវចេញពីផ្ទះ គាត់បានទៅឈរនៅមាត់ទ្វារម្តាយរបស់គាត់ ដោយផ្ទះរបស់អាហ្គីហ៊ូរ៉ៃរ៉ោះ និងផ្ទះម្តាយរបស់គាត់នៅផ្សេងពីគ្នា) ។គាត់បានធ្វើគារវកិច្ចទៅកាន់ម្តាយរបស់គាត់ដោយពោលថា: **السلام عليك ورحمة الله** ឱអ្នកម្តាយជាទីសំលាញ់! ។ ម្តាយបានតបវិញដោយពោលថា: **وعليك السلا م ورحمة الله** ឱកូនសំលាញ់!



គាត់ពោលទៀតថា: " អល់ឡោះនឹងប្រទាននូវការសណ្តោសប្រណីដល់អ្នកម្តាយដូចដែលអ្នកម្តាយបានបីបាច់ថែរក្សាខ្ញុំតាំងពីតូចមក។ ម្តាយក៏បានពោលទៅវិញថា: អល់ឡោះនឹងសណ្តោសប្រណីអាណិតអាសូរដល់កូនដោយកូនបានយកចិត្តទុកដាក់តបស្នងសងគុណដល់ម្តាយ ពេលម្តាយជរា។ នៅពេលរៀបចូលផ្ទះលោកក៏ធ្វើរបៀបនេះដែរ" ។

*(ដកស្រង់ពីសៀវភៅអាហ្ទើបមូហ្វារ៉ តរបស់ហ្គូខរី )* ។

**៤-**អាណាសកូនអាន់ណាត្ស៊ីរអាល់អាសយ៉ាអ៊ុបានពោលថា: ម្តាយរបស់អ៊ិបនូម៉ាសអ៊ូដបានសុំទឹកផឹកនាយប់មួយ។ ពេលនោះអ៊ិបនូម៉ាសអ៊ូដក៏ទៅយកទឹកអោយម្តាយ តែពេលដែលលោកបានយកទឹកមក ស្រាប់តែម្តាយរបស់គាត់បានដេកលក់ទៅហើយ គាត់បានទុកទឹកនៅក្បែរខាងក្បាលម្តាយរបស់គាត់រហូតដល់ពេលព្រឹក។

*(ដកស្រង់ពីសៀវភៅហ្គៀវរុលវ៉ាលីឌៃនីរបស់អាល់ដៅហ្ស៊ី )* ។

**៥-** លោកសាហ្វយ៉ានកូនអ៊ូយ៉ៃណះបានពោលថា: បុរសម្នាក់បានវិលត្រលប់មកពីការធ្វើដំណើរវិញ ស្រាប់តែគាត់បានឃើញម្តាយរបស់គាត់កំពុងឈរសឡាហ៍។ បុរសនោះមិនហ៊ានអង្គុយចុះឡើយខណៈដែលម្តាយរបស់គាត់កំពុងឈរ។ ម្តាយរបស់គាត់បានដឹងពីបំណងរបស់កូន គាត់ក៏បន្តឈរសឡាហ៍អោយកាន់តែយូរដើម្បីឱ្យកូនរបស់គាត់ទទួលបានផលបុណ្យពីអល់ឡោះកាន់តែច្រើន។

*(ដកស្រង់ពីសៀវភៅហ្គៀវរុលវ៉ាលីឌៃនីរបស់អិបនូអាល់ដៅហ្ស៊ី)*

៦- លោកហ៊ីវ៉ាស់ កូនស៊្វូរ៉ៃហ៏ ជាថ្នាក់ដឹកនាំអ៊ីស្លាមម្នាក់ ។ ថ្ងៃមួយគាត់កំពុងអង្គុយបង្រៀនមនុស្សម្នា ស្រាប់តែពេលនោះម្តាយរបស់គាត់បានមកដល់ រួចនិយាយទៅកាន់គាត់ថាៈ ឱហ៊ីវ៉ាស់! ទៅយកស្រូវសាលីដាក់អោយមាន់ស៊ី ។ លោកហ៊ីវ៉ាស់បានក្រោកឈរធ្វើតាមបញ្ជាម្តាយដោយផ្អាកការបង្រៀនសិន ។

*(ដងស្រង់ពីអាល់ហ្ពៀវរ៉ាអាល់សីឡះរបស់អិបនូអាល់ហ្ចៅហ៊្សី)* ។

៧-លោកកាស់ម៉ាសកូនអាល់ហាសាន់ អាត់តាមីមីបានឃើញសត្វក្អែបមួយវារនៅក្នុងផ្ទះរបស់គាត់ ។ គាត់មានបំណងចង់សំលាប់ក្អែបនោះឬយកវាចេញពីផ្ទះ ។ គាត់ក៏ដេញចាប់ក្អែបនោះ ចាប់មិនទាន់បានផង ក្អែបនោះក៏រត់ចូលរន្ធបាត់ទៅ ។ ពេលនោះគាត់លូកដៃចូលក្នុងរន្ធដើម្បីចាប់ តែត្រូវបានសត្វក្អែបខាំដៃរបស់គាត់ ។មានគេនិយាយទៅកាន់គាត់ថាៈ តើអ្នកមានបំណងអ្វីបានជាធ្វើដូចនេះ?" គាត់ឆ្លើយថាៈ" ពិតណាស់ខ្ញុំខ្លាចក្រែងសត្វក្អែបនេះវារចេញពីរន្ធ ហើយទៅខាំម្តាយរបស់ខ្ញុំ " ។

*(ដកស្រង់ពីសៀវភៅនូសហះអាល់ហ្វាឌូឡា)* ។

៨- មូហាំម៉ាត់កូនស៊ីរីនបានបញ្ជាក់ថាៈ តំលៃដើមល្មើនៅសម័យឧស្មានកូនអាហ្វហ្វានមួយដើមមានតំលៃ១០០០ឌៀរហាំ[៤] ។ខណៈនោះលោកអ៊ូសាម៉ះកូនហ្សៃតក៏ទៅកាប់ដើមល្មើ រួចយកគម (បណ្តូល) វាទៅអោយម្តាយរបស់លោកពិសារ ។ ខណៈនោះមនុស្សម្នាបានសួរលោកថាៈ ហេតុអ្វីបានជាអ្នក

---

៤-ឌៀរហាំជាឈ្មោះរូបិយប័ណ្ណនៅប្រទេសអារាប់សម័យដើម ។



ធ្វើដូច្នេះ តំលៃដើមល្មើមួយដើម១០០០ឌៀរហាំ!!! ។ គាត់ឆ្លើយថាៈ" ម្តាយរបស់ខ្ញុំបានសំណូមពរខ្ញុំ (រឿងគមល្មើ) អ្វីក៏ដោយអោយតែម្តាយខ្ញុំស្នើសុំហើយខ្ញុំមានលទ្ធភាពនោះខ្ញុំនឹងផ្តល់ជូនលោកអ្នកមានគុណមិនខាន" ។

*(ដកស្រង់ពីសៀវភៅស៊ីហ្វះអាស់សហ្វវ៉ះ)* ។

៩-ហាប់សោះកូនស្រីស៊ីរីនបានពោលថាៈ ម្តាយរបស់លោកមូហាំម៉ាត់ កូនស៊ីរីនចូលចិត្តការជ្រលក់ពណិសំលៀកបំពាក់ ។ នៅពេលណាលោកមូហាំម៉ាត់ទិញសំលៀកបំពាក់ជូនម្តាយលោក លោកតែងតែទិញក្រណាត់សាច់ទន់ ។ ពេលណាចូលដល់ថ្ងៃបុណ្យទាន លោកជ្រលក់ពណិសំលៀកបំពាក់អោយម្តាយរបស់លោក ។ ខ្ញុំ (ហាប់សោះ) មិនដែលឃើញលោកនិយាយសំលេងខ្លាំងដាក់ម្តាយរបស់គាត់ម្តងណាឡើយ ពោលគឺពេលណាដែលលោកត្រូវនិយាយជាមួយម្តាយ គឺលោកប្រើសំលេងទន់ភ្លន់ដូចជាក្រណាត់ជ្រលក់ពណិដែរ ។

*(ដកស្រង់ពីសៀវភៅសៀវអាក់ឡាមនូហ្គើឡា)* ។

១០- លោកអ៊ិបនូអៅនីបានពោលថាៈ មានបុរសម្នាក់បានចូលជួបមូហាំម៉ាត់កូនស៊ីរីនដែលកំពុងនៅជិតម្តាយរបស់គាត់ ។បុរសនោះសួរថាៈតើមូហាំម៉ាត់មានរឿងអ្វី? ។ ពួកគេបានឆ្លើយថាៈ ទេ! មិនស្អីទេ តែកាលណាគាត់នៅជិតម្តាយរបស់គាត់ គាត់តែងមានសភាពបែបនេះ ។

*(ដកស្រង់ពីសៀវភៅសៀវអាក់ឡាមនូហ្គើឡា )* ។

១១-លោកហាមីដបានពោលថាៈ នៅពេលដែលម្តាយរបស់អ៊ីយ៉ាសកូន

មូអាវីយ៉ះស្លាប់ អុីយ៉ាសបានយំ ខណៈនោះមានគេសួរលោកថាៈអ្វីទៅដែលធ្វើអោយអ្នកយំ? ។ គាត់ឆ្លើយថាៈ" ជាការពិតខ្ញុំមានទ្វារចំនួនពីរដែលកំពុងបើកចំហឆ្ពោះទៅកាន់ឋានសួគ៌ តែឥឡូវនេះគេបិទទ្វារមួយទៅហើយ ។

*(ដកស្រង់ពីសៀវភៅអាល់ហ្ពៀរវាសិឡះរបស់អុិបនូជៅហ្សុី)*

បងប្អូនមូស្លីមជាទីស្រលាញ់! សកម្មភាពនៃការធ្វើល្អចំពោះឪពុក ម្តាយរបស់អ្នកសម័យមុនៗ គឺពួកយើងបានឃើញនិងភ្លក្សរសជាតិវាហើយ ។ ពួកគេបានយកចិត្តទុកដាក់ខ្លាំងណាស់ ចំពោះការធ្វើល្អចំពោះអ្នកមានគុណទាំងពីរ គេហ៊ានលះបង់អ្វីៗទាំងអស់ដើម្បីឪពុកម្តាយរបស់គេ ។តែពេលបច្ចុប្បន្នវិញ គឺមានការប្រែប្រួលស្ទើរតែមិនអាចជឿបាន នោះគឺមនុស្សភាគច្រើនបែរជាមិនគិតពីសារៈសំខាន់នៃការធ្វើអំពើល្អចំពោះមាតា បិតារបស់ខ្លួនទៅវិញ ។

## អំពើអកតញ្ញូចំពោះមាតាបិតា

ទង្វើអកតញ្ញូចំពោះឪពុកម្តាយ ជាបាបកម្មដ៏ធំមួយក្នុងចំណោមបាបកម្មធំៗផ្សេងទៀត ។ វាជាបាបកម្មធំដែលជាបរិវានៃអំពើស្ហ៊ីរិកចំពោះអល់ឡោះ ដែលត្រូវតែទទួលទណ្ឌកម្មនៅក្នុងលោកិយ៏ និងជាមូលហេតុនាំអោយធ្លាក់នរកនាថ្ងៃបរលោក វាជាអំពើប្រឆាំងនឹងកុសលផលបុណ្យ ប្រឆាំងនឹងភាពថ្លៃថ្នូរក្នុងសង្គម វារុញច្រានអ្នកប្រព្រឹត្តអោយក្លាយជាជនអគតិ ជនអវិជ្ជាជនថោកទាបក្នុងសង្គម ជនដែលគ្មានតំលៃវាជារឿងដែលពិបាកអោយតំលៃ ។ ហើយវានាំអោយបាត់បង់ខ្សែលោហិតជាមួយអ្នកមានគុណទាំងពីរវាឃ្លាត



ឆ្ងាយពីសេចក្តីស្រឡាញ់និងការថ្នាក់ថ្នម ។

អាស្រ័យដូចបានបង្ហាញជូនខាងលើនេះ ច្បាប់នៃសាសនាអុីស្លាមបានធ្វើការព្រមានខ្លាំងៗបំផុតចំពោះជនអកតញ្ញូ ហើយបានបង្ហាញដល់ជនប្រភេទនោះអោយងាកមកធ្វើល្អចំពោះមាតាបិតារបស់ខ្លួនឡើងវិញ ដោយបញ្ជាក់ថាៈ ផលកម្មចុងក្រោយរបស់គេនឹងវិនាសអន្តរាយទាំងលោកិយ៏ និងបរលោក ។ ដូចអ្វីដែលណាហ្ពីយើងមូហាំម៉ាត់បានមានប្រសាសន៏ថាៈ

عن أَبِي هريرةَ رضي اللهُ عنه قَالَ : سمعت رسولَ اللهِ صلى اللهُ علَيه وسلم يقُولُ : { رغم أَنفه، رغم أَنفه، رغم أَنفه } قيلَ: من يا رسولَ اللهِ؟ قَالَ: { من أَدرك والديه عند الْكبرِ أَحدهما أَو كلَيهما ثُم لَم يدخلِ الْجنةَ } (رواه مسلم والترمذي)

មានន័យថាៈ អាហ្ពូហ៊ូរ៉ៃយ៉រ៉ោះបានពោលថាៈ ខ្ញុំបានលឺរ៉ស៊ូលុលឡោះមានប្រសាសន៏ថាៈ ថោកទាបណាស់! ថោកទាបណាស់! ថោកទាបណាស់! មានគេសួរលោកថាៈឱរ៉ស៊ូលុលឡោះ! តើនរណាទៅ? លោកមានប្រសាសន៏ថាៈ ( គឺអ្នកដែលមានជីវិតទាន់ឪពុកម្តាយ ឬម្នាក់ក្នុងចំណោមអ្នកទាំងពីរចូលដល់វ័យចាស់ជរា តែរូបគេ( ជាកូន) បែរជាមិនបានចូលឋានសួគ៌( ដោយសារកូនរូបនោះមិនបានធ្វើល្អចំពោះឪពុកម្តាយដែលជាហេតុនាំអោយខ្លួនចូលឋានសួគ៌) ។

## ក្នុងចំណោមអំពើអកតញ្ញូចំពោះមាតាបិតា

**១**-ការមិនឧបត្ថម្ភចិញ្ចឹមលោកទាំងពីរ ក្នុងពេលលោកទាំងពីរត្រូវការជំនួយ ។ កូនៗត្រូវដឹងថាៈការទទួលខុសត្រូវនិងការផ្គត់ផ្គង់ដល់អ្នកមានគុណជាបន្ទុករបស់កូន ជាពិសេសក្នុងពេលលោកទាំងពីរចូលវ័យចាស់ជរានិងទន់ខ្សោយ ។ ការផ្គត់ផ្គង់នឹងក្លាយជាកាតព្វកិច្ច ដែលគេដាក់បន្ទុកកម្មផលឬបាបកម្មទៅលើកូនៗទាំងលោកីយ៍និងបរលោក ក្នុងពេលដែលលោកទាំងពីរតំរូវការជំនួយនោះ! តែកូនមិនបានបំពេញវា ។

មានសេចក្តីរាយការណ៍អំពីអ៊ិបនូម៉ាយ៉េសថាៈជាការពិតណាស់មានបុរសម្នាក់បានទៅជួបណាហ្ពីហើយបាននិយាយរៀបរាប់ប្រាប់លោកថាៈ " ឱរ៉សូលុលឡោះ! ជាការពិតណាស់ ខ្ញុំមានទ្រព្យសម្បត្តិនិងកូន ហើយឪពុករបស់ខ្ញុំមានបំណងត្រួតត្រាទ្រព្យសម្បត្តិរបស់ខ្ញុំ ( គាត់ត្រូវការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្ញុំ) ។ ខណៈនោះរ៉សូលុលឡោះបានមានប្រសាសន៍ថាៈ

(أنت ومالُك لأَبِيك) رواه ابن ماجه وصححه الألباني .

មានន័យថាៈខ្លួនប្រាណនិងទ្រព្យសម្បត្តិរបស់អ្នកជាកម្មសិទ្ធិរបស់ឪពុកអ្នក ។

ក្នុងចំណោមបាបកម្មនិងអកតញ្ញូដ៏ធំផេងនោះ គឺកូនដែលមិនជួយឧបត្ថម្ភដល់ឪពុកម្តាយ ករណីនេះថ្នាក់ដឹកនាំត្រូវតែចាប់បង្ខំកូនរូបនោះអោយជួយឧបត្ថម្ភដល់ឪពុក ម្តាយរបស់ខ្លួន ។

**២**-ការមិនបំរើឪពុកម្តាយរបស់ខ្លួននឹងវាកាន់តែធ្ងន់ធ្ងរថែមទៀតគឺទុកអ្នកមានគុណទាំងពីររស់ដោយខ្លួនឯង ។ ចាត់ជាកំហុសផងដែរការមិនជួយកិច្ចការដល់



ពួកគាត់ទាំងពីរសូម្បីតែជាការរៀបចំសំអាតផ្ទះសំបែងឬចំណីអាហារក៏ដោយ ។

**៣**-ការធ្វើអោយអ្នកមានគុណទាំងពីរហូរទឹកភ្នែកនិងទុក្ខព្រួយក្នុងចិត្តតាមរយៈពាក្យសំដីក្តីកាយវិការក្តីឬតាមរយៈទង្វើផ្សេងៗ ។មានសេចក្តីរាយការណ៍មួយដោយអាហ្ពីដាវូដថាៈ មានបុរសម្នាក់បានមកជួបណាហ្ពីរួចបាននិយាយទៅកាន់លោកថាៈ ខ្ញុំមកនេះដើម្បីសច្ចាជាមួយលោក ខ្ញុំនឹងភៀសខ្លួនជាមួយលោកតែខ្ញុំបានទុកអ្នកមានគុណទាំងពីរនៅបង្ហូរទឹកភ្នែក ។ខណៈនោះណាហ្ពីបានមានប្រសាសន៍ទៅកាន់បុរសនោះថាៈ

( ارجِع إِلَيهما فَأَضحكْهما كَما أَبكَيتهما) رواه أبو داود وصححه الألباني

**មានន័យថាៈ ចូរអ្នកវិលត្រលប់ទៅជួបអ្នកទាំងពីរវិញ ហើយអ្នកត្រូវលួងលោមអោយពួកគាត់សើចសប្បាយដូចជាអ្នកបានធ្វើអោយពួកគាត់ទាំងពីរហូរទឹកភ្នែកអញ្ចឹងដែរ ។**

អ៊ីបនូអ៊ូម៉ើរបាននិយាយថាៈ ការបង្កហេតុធ្វើអោយឪពុកម្តាយហូរទឹកភ្នែកគឺជាអំពើអកតញ្ញូហើយស្ថិតក្នុងចំណោមបាបកម្មដ៏ធំ ។មានមតិខ្លះបានលើកឡើងថាៈ បុគ្គលណាក៏ដោយគ្រាន់តែធ្វើអោយឪពុកម្តាយមានការព្រួយបារម្ភបុគ្គលនោះកំពុងតែប្រព្រឹត្តអំពើអកតញ្ញូចំពោះមាតាបិតាហើយ ។

**៤**-ការប្រើពាក្យៈ យីសយូស ឬ ការប្រើសំលេងខ្លាំងៗនៅចំពោះមុខលោកអ្នកមានគុណទាំងពីរ ឬក៏ការបង្ខំលោកទាំងពីរអោយស្តាប់ពាក្យពេចន៍ដែលអសុរសរបស់ខ្លួន ក្នុងករណីមានការខ្វែងទស្សនៈគ្នាបន្តិចបន្តួច ។ ទាំងនេះចាត់ទុកជាការមើលស្រាលដល់អ្នកមានគុណទាំងពីរខ្លាំងណាស់ ជាពិសេស

បើកូនជាអ្នកមានចំណេះដឹងជ្រៅជ្រះ ហើយឪពុកមិនបានរៀនសូត្រនោះ ។
៥-ការសំឡក់សំលឹង ឬការសំលឹងដោយប្រើកន្ទុយភ្នែកដៀងទៅរកលោកទាំងពីរនៅពេលមានកំហឹង ។មានគេអះអាងថាៈមិនចាត់ជាកូនកតញ្ញូឡើយចំពោះកូនណាដែលសំឡក់សំលឹងចុងភ្នែកទៅកាន់អ្នកមានគុណទាំងពីរក្នុងពេលមានកំហឹងនោះ ។
៦-ការយកកន្លែងអង្គុយមុនលោកទាំងពីរ ដោយមិនខ្វល់ពីលោកទាំងពីរ ។ ចាប់ផ្តើមនិយាយដោយគ្មានការអនុញ្ញាតិពីសំណាក់លោកទាំងពីរ ។ បើធ្វើទង្វើទាំងនោះ គឺវាបង្ហាញពីមោទនភាព ដែលវាជាមូលហេតុធ្វើអោយចិត្តរបស់ឪពុកម្តាយសៅហ្មងទៅលើកូនរបស់ខ្លួន និងធ្វើអោយអល់ឡោះម្ចាស់ខឹងសម្បារដល់កូនប្រភេទនេះមិនខាន ។
៧-ការបដិសេធមតិយោបល់របស់អ្នកទាំងពីរ បោះបង់ការពិភាក្សាជាមួយអ្នកទាំងពីរ និងការមិនសុំយោបល់ក្នុងកិច្ចការអ្វីមួយពីអ្នកទាំងពីរ ទោះបីការរៀបអាពាហ៍ពិពាហ៍ ការធ្វើដំណើរ ឬការចេញពីគេហដ្ឋានក៏ដោយ ។
៨-ការមិនស្តាប់ដំបូន្មានរបស់លោកទាំងពីរ ការព្យាយាមនិយាយកាត់ពាក្យសំដីលោកទាំងពីរ និងការប្រឆាំងតវ៉ាចំពោះលោកទាំងពីរជាដើម ។
៩-ការមិនក្រោកឈរមុនលោកទាំងពីរ និងការមិនថើបដៃទាំងពីររបស់ពួកគាត់នៅពេលចូលជួបសំដែងការគួរសមជាមួយគាត់ ។ តាមពិតការងារទាំងនេះគេអាចធ្វើបាន ក្នុងន័យលើកតំកើងដល់អ្នកមានគុណនិងអ្នកដែលមានចំណេះដឹងខ្ពង់ខ្ពស់ ចុះបើលោកទាំងពីរជាអ្នកមានគុណទៀតនោះ គឺវាកាន់តែត្រូវធ្វើចំពោះលោកទាំងពីរទៀត ព្រោះឋានៈនិងតួនាទីរបស់គាត់ទាំងពីរទ្វេរដងនៃអ្នកដទៃ ហើយការសំដែងពីសុជីវធម៌ចំពោះពួកគាត់ជាការចាំបាច់បំផុត ។



១០- កូនខ្លះដោយលង់នឹងការបោកប្រាស់ គេខ្មាស់អៀនមិនហ៊ានប្រើត្រកូលឪពុករបស់គេទេឬគេមិនហ៊ានបង្ហាញអោយគេស្គាល់ឪពុករបស់ខ្លួនក្នុងសហគមន៍ ជាពិសេសនោះ បើកូនមានតួនាទីខ្ពង់ខ្ពស់នៅក្នុងសហគមន៍ ឬក្នុងតំណែងកាន់លុយកាក់ ហើយឪពុករបស់គេមានត្រឹមការងារតូចតាចនោះ! ទាំងនេះគឺបង្ហាញពីភាពទន់ខ្សោយផ្នែកសាសនានិងស្មារតី ។ ខ្លួនដែលថ្មីថ្មើងថ្លៃថ្នូរ គឺបង្ហាញពីមោទនភាពនៃធាតុដើមរបស់ខ្លួន ទោះបីជាដំណើរជីវិតរបស់អ្នកមានគុណទាំងពីរ ការរស់នៅរបស់អ្នកមានគុណទាំងពីរក្នុងស្ថានភាពបែបណាក៏ដោយ ។
១១-ការបណ្តេញលោកទាំងពីរអោយចាកចេញពីផ្ទះ និងការបញ្ជូនពួកគាត់អោយទៅរស់នៅក្នុងមជ្ឈមណ្ឌលចាស់ជរា ដើម្បីអោយរួចផុតពីការទទួលខុសត្រូវនិងការចំណាយទៅលើអ្នកមានគុណទាំងពីរ ។ អាកប្បកិរិយាបែបនេះ គឺជាទង្វើសាហាវព្រៃផ្សៃជូជាតិ ដាច់ធម៌មេត្តា ផ្តាច់មនោសញ្ចេតនា និងជាទង្វើដែលគួរអោយស្អប់ខ្ពើមបំផុត ។
១២-ការនាំប្រការអាក្រក់ៗចូលផ្ទះ ឬធ្វើកាយវិការមិនសមរម្យនៅចំពោះមុខលោកអ្នកមានគុណទាំងពីរ ដូចជា ការនាំមកប្រើប្រាស់នូវឧបករណ៍តន្ត្រី ឬស្តាប់តន្ត្រី និងពាក្យពេចន៍មិនគប្បីផ្សេងៗចូលក្នុងផ្ទះរបស់លោកអ្នកមានគុណទាំងពីរ ការជក់បារី ការប្រើប្រាស់គ្រឿងញៀនការមើលរឿងអាស

អាកាស និងរូបអាក្រាតផ្សេងៗ ការបោះបង់ចោលសឡាហ៍ ផឹកសុរា និងនាំមិត្តភក្តិ ខិលខូចចូលក្នុងផ្ទះលោកទាំងពីរជាដើម ។ល ។

**១៣-** ការជេរតិះដៀល ការប្រមាថមើលងាយ ការប្រទេចផ្តាសាលោកអ្នកមានគុណទាំងពីរ ទោះប្រព្រឹត្តដោយផ្ទាល់ ឬដោយប្រយោល ។

ណាហ្គីបានមានប្រសាសន៍ថា:

(إن من أَكْبرِ الْكَبائرِ أَنْ يلْعن الرجلُ والديه ، قيلَ يا رسولَ اللهِ وكَيف يلْعن الرجلُ والديه ؟ قَالَ : يسب أَبا الرجلِ ، فَيسب أَباه ،ويسب أُمه فَيسب أُمه)

មានន័យថា: ជាការពិតណាស់ក្នុងចំណោមបាបកម្មធំៗ គឺបុគ្គលណាម្នាក់ដាក់បណ្តាសាឪពុកម្តាយរបស់ខ្លួន ។ មានគេសួរលោកថា:ឱរ៉សូលុលឡោះ! តើបុគ្គលម្នាក់ដាក់បណ្តាសាឪពុកម្តាយរបស់ខ្លួនយ៉ាងដូចម្តេច? ។ លោកមានប្រសាសន៍ថា:(គឺបុរសម្នាក់ជេរឪពុកអ្នកដទៃ ហើយបុរសដទៃនោះ ក៏ជេរឪពុកខ្លួនវិញ ហើយគេជេរម្តាយអ្នកដទៃ ហើយអ្នកដទៃនោះក៏ជេរម្តាយខ្លួនវិញនោះហើយជាការដាក់បណ្តាសាដល់លោកទាំងពីរ ។

وفي رواية : ( من الْكَبائرِ شتم الرجلُ والديه) متفق عليه.

នៅក្នុងសេចក្តីរាយការណ៍មួយផ្សេងទៀតបញ្ជាក់ថា:(ក្នុងចំណោមបាបកម្មធំៗ នោះ គឺបុរសម្នាក់ជេរតិះដៀលឪពុកម្តាយរបស់ខ្លួន) ។

*(រាយការណ៍ហាហ្ទីស្សដោយអ៊ីម៉ាំហ្ពូខរី និងមូស្លីម )*

**១៤-** ការនិយាយដើម ការលើកឡើងអំពីលក្ខណៈខ្វះខាត និងការចំអកបរិហារកេរ្តិ៍អាថិកំបាំងរបស់អ្នកមានគុណទាំងពីរក្នុងចំណោមមនុស្សម្នា ។



ទង្វើទាំងនេះត្រូវបានច្បាប់ហាមឃាត់ចំពោះមនុស្សទូទៅ ចុះទំរាំពួកគាត់ជាអ្នកមានគុណនោះ តើវាយ៉ាងណាទៅវិញ!!!? ។

**១៥-**ការស្តាប់បង្គាប់ភរិយាជាងឪពុកម្តាយ ។ ករណីបែបនេះ វាបាននិងកំពុងកើតមានយ៉ាងផុសផុលនាបច្ចុប្បន្នភាពនេះ ។ ការកតញ្ញូចំពោះឪពុកម្តាយប្រសើរជាងសឡាហ៍ស៊ូណាត់ទៅទៀត កូនៗត្រូវគេចាត់ទុកថាមានបាបកម្មបើគេធ្វើសឡាហ៍ស៊ូណាត់ជាងការធ្វើកតញ្ញូចំពោះឪពុកម្តាយនោះ! ។ ដូចមានរឿងមួយនិយាយពីបុរសម្នាក់ឈ្មោះជូរៃហ៍ម្តាយគាត់មកហៅក្នុងពេលដែលគាត់កំពុងសឡាហ៍ស៊ូណាត់នោះ ។

(ដងស្រង់ពីសៀវភៅហ្ពូខរីនិងមូស្លីម)

ចុះទំរាំអ្នកដែលស្តាប់បង្គាប់ភរិយាជាងឪពុកម្តាយនោះយ៉ាងណាទៅវិញ! ។

**១៦-** ការប្រាថ្នាអោយអ្នកមានគុណទាំងពីរឆាប់ស្លាប់ ដើម្បីគេនឹងឆាប់បានទទួលមរតក បើលោកទាំងពីរជាអ្នកមាន ឬដើម្បីអោយគេឆាប់បានរួចពីបន្ទុកនៃការទទួលខុសលើអ្នកមានគុណទាំងពីរបើលោកទាំងពីរជាអ្នកក្រីក្រ ឬក៏គេចចេញពីការបីបាច់ថែរក្សាឬពីការប្រឈមមុខនឹងទោសកំហុសក្នុងករណីដែលខ្លួនធ្វើអំពើអកតញ្ញូចំពោះលោកទាំងពីរ ។

រូបភាពនៃទង្វើទាំងអស់នេះ ជាអំពើអកតញ្ញូគួរអោយស្អប់ខ្ពើមជាទីបំផុត ។

## កម្មផលរបស់ជនអកតញ្ញូ

**១-អល់ឡោះមិនមើលទៅជនអកតញ្ញូ ហើយទ្រង់នឹងមិនបញ្ចូលរូបគេទៅក្នុងឋានសួគ៌ឡើយ ។**

ពីអាប់ឌុលឡោះកូនរបស់អ៊ូម៉ើរបាននិយាយថាៈ ណាប៊ីមានប្រសាសន៍ថាៈ

( ثَلاَثَةٌ لاَ ينظُر اللهُ إلَيهم يوم القِيامة: اَلْعاق لوالديه والْمرأةُ الْمترجلَةُ الْمتشبهةُ بِالرجال ،والديوثُ . وثَلاَثَةٌ لاَ يدخلُونَ الْجنةَ: اَلْعاق لوالديه ،والْمدمن الْخمر ،والْمنانُ بِما أعطَى ) رواه أحمد والنسائي

មានន័យថាៈមនុស្សបីប្រភេទដែលអល់ឡោះមិនមើលទៅកាន់ពួកគេនៅថ្ងៃបរលោកនោះគឺៈជនអកតញ្ញូចំពោះឪពុកម្តាយ ស្ត្រីភេទដែលសំដែងឫកពារជាបុរសភេទ និងស្រីផិតប្តី រីឯមនុស្សបីប្រភេទផ្សេងទៀតដែលមិនបានចូលឋានសួគ៌នោះ គឺជនអកតញ្ញូចំពោះឪពុកម្តាយ ជនប្រមឹកនឹងគ្រឿងស្រវឹង និងជនដែល តំកើងខ្លួននៅពេលដែលខ្លួនបានផ្តល់អ្វីទៅអោយគេ ។

*(រាយការណ៍ដោយអ៊ីម៉ាំអះម៉ាត់និងណាសើអ៊ី)*

**២- អល់ឡោះមិនទទួលយកការសារភាពកំហុស និងការបង់ពិន័យពីជនអកតញ្ញូឡើយ ។**

អំពីអាប៊ីអ៊ូម៉ាម៉ះបានពោលថា : រ៉សូ៊លុលឡោះមានប្រសាសន៍ថាៈ

( ثَلاَثَةٌ لا يقْبَلُ الله منهم صرفًا ولا عدلا: عاق ، ومنانٌ ، ومكَذب بِالْقَدرِ " رواه الطبراني في الكبير.

មានន័យថាៈ មនុស្សបីប្រភេទដែលអល់ឡោះមិនទទួលយកការសារភាព



ទោសកំហុសនិងការបង់ពិន័យរបស់ពួកគេឡើយ ។ ជនទាំងនោះគឺៈជនអកតញ្ញូចំពោះឪពុកម្តាយ ជនដែលតំកើងខ្លួនពីអ្វីដែលខ្លួនបានផ្តល់អោយគេ អ្នកដែលគ្មានជំនឿលើការកំណត់ព្រេងវាសនាពីអល់ឡោះ ។

*(រាយការណ៍ដោយអាត់តប់រ៉នី)*

**៣-អល់ឡោះនឹងដាក់បណ្តាសារចំពោះជនអកតញ្ញូ ។**

អំពីអាលីបានពោលថាៈរ៉សូ៊លុលឡោះបានមានប្រសាសន៏ថាៈ

( لَعن اللهُ من ذَبح لغيرِ اللهِ، لَعن اللهُ من لَعن والديه، لَعن اللهُ من آوى محدثًا، لَعن اللهُ من غَير منار الْأَرض ) رواه مسلم .

មានន័យថាៈ អល់ឡោះបានដាក់បណ្តាសាចំពោះអ្នកសំឡេះសត្វក្នុងទិសដៅផ្សេងពីអល់ឡោះ ។ អល់ឡោះបានដាក់បណ្តាសាចំពោះជនដែលបានដាក់បណ្តាសារឪពុកម្តាយរបស់ខ្លួន ។ អល់ឡោះបានដាក់បណ្តាសាចំពោះអ្នកដែលជួយគាំទ្រអ៊ីហ្គើដាត់ដែលគ្មានភស្តុតាង( អំពើហ្ពិតអះ) ។អល់ឡោះបានដាក់បណ្តាសាចំពោះអ្នកដែលបង្ខិតព្រំដី ( រំាតទីយកដីធ្លីអ្នកជិត ខាង) ។

**៤-ជាការពិតណាស់អល់ឡោះមិនស្រលាញ់ជនអកតញ្ញូឡើយ ។**

ពីអាប់ឌុលឡោះកូនអាំរូកូនអាស្វបាននិយាយថាៈពិតណាស់រ៉សូ៊លុលឡោះបានមានប្រសាសន៏ថា :

( إِن اللهَ لاَ يحب الْعقُوق )

មានន័យថាៈ អល់ឡោះពិតជាមិនពេញចិត្តជនចំពោះអកតញ្ញូតាធមិឡើយ ។

*(រាយការណ៏ដោយអះម៉ាត់)*

**៥-អល់ឡោះពិតជាបានត្រៀមទុកសំរាប់ជនអកតញ្ញូនូវឋាននរក ។**

អាហ្គីហ្វឺរ៉ោះពោលថា : ពិតណាស់រ៉ស៊ូលុលឡោះបានមានប្រសាសន៍ថាៈ ជីបរ៉អ៊ីលបានមកជួបខ្ញុំរួចនិយាយថាៈ

( ومن أدرك أبويه أو أحدهما فلم يبرهما فمات فدخلَ النار فأبعده الله، قُلْ : آمين ، فَقُلْت : آمين ) رواه ابن حبان وهو حسن

មានន័យថាៈ ពិតណាស់ជីបរ៉អ៊ីលបានមកជួបខ្ញុំ ហើយមានប្រសាសន៍ថាៈបុគ្គលណានៅមានជីវិតទាន់ឪពុកម្តាយរបស់គេ ឬទាន់ម្នាក់ក្នុងចំណោមពួកគាត់ទាំងពីរ ហើយគេបែរជាមិនបានធ្វើល្អចំពោះលោកទាំងពីរទេ រហូតដល់រូបគេបានទទួលមរណះភាព។ បុគ្គលប្រភេទនេះនឹងចូលឋាននរក ហើយអល់ឡោះនឹងអោយជនប្រភេទនេះនៅឆ្ងាយពីទ្រង់( មិនខ្វល់ពីគេឡើយ) ។ ជីបរ៉អ៊ីលបានប្រើខ្ញុំថា :ឱមូហាំម៉ាត់ ! ចូរអ្នកពោលថា **آمين** ខ្ញុំក៏ពោលថា **آمين** ។

៦-ជនអកតញ្ញូជាជនប្រព្រឹត្តបាបកម្មធំមួយក្នុងចំណោមបាបកម្មធំៗទាំងឡាយ ។ អំពីអាហ្ពូហ្ពាកើរពោលថាៈ រ៉ស៊ូលុលឡោះមានប្រសាសន៍ថាៈ

قَالَ رسولُ اللهِ صلى الله عليه وسلم :(ألاَ أنبئُكُم بِأَكْبرِ الْكَبائرِ؟ قُلْنا :بلَى يا رسولَ اللهِ ، قالَ : الْإِشراك بِاللهِ، وعقُوق الْوالدينِ وكاَنَ متكئًا فَجلَس ،وقَالَ : ألاَ وقَولُ الزورِ ، وشهادةَ الزورِ، فَمازالَ يكَررها حتى قُلْنا : لَيته سكَت ) متفق عليه

មានន័យថាៈ" តើខ្ញុំមិនបានប្រាប់ពួកអ្នកទាំងអស់គ្នានូវអំពើបាបកម្មធំឬទេ?" ពួកយើងឆ្លើយថាៈ ពិតមែនហើយឱរ៉ស៊ូលុលឡោះ! ។ លោកបានមានប្រសាសន៍បន្តថាៈ" បាបកម្មធំនោះគឺការប្រព្រឹត្តអំពើស្ហ៊ីរិក និងការធ្វើអំពើ



អកតញ្ញូចំពោះឪពុកម្តាយ" ។ ពេលនោះលោកនៅផ្អែក បន្ទាប់មកលោកអង្គុយរួចមានប្រសាសន៍ទៀតថាៈ" ពាក្យប្រឌិតនិងការធ្វើសាក្សីប្រឌិត"!!! លោកមានប្រសាសន៍របៀបនេះដដែលៗជាច្រើនលើក រហូតដល់ពួកយើងប្រាថ្នាថាៈ សូមលោកឈប់មានប្រសាសន៍ចុះ ។

**៧- ជនអកតញ្ញូពិតជារស់នៅក្នុងសភាពលំបាកជានិច្ច ឃ្លាតឆ្ងាយពីចិត្តមេត្តាធម៌និងការរាប់រករបស់មនុស្សទាំងឡាយ ។**

សំរាប់ជនប្រភេទនេះគ្មានមិត្តភក្តិរាប់រកទេ គ្មានអ្នកជាទីស្រឡាញ់រាប់រកទេ គ្មានបងប្អូននិងសាច់សាលោហិតណារាប់រកទេ ។មនុស្សម្នាមិនខ្វល់ចំពោះជនប្រភេទនេះក្នុងពេលគេជួបគ្រោះថ្នាក់ ហើយមនុស្សម្នាក៏គេមិនចូលចិត្តរាប់អានជនប្រភេទនេះដែរ ដោយខ្លាចជននេះអូសទាញកូនចៅរបស់គេអោយក្លាយទៅជាជនអកតញ្ញូដូចរូបជននោះដែរ ។

**វាខុសពីអ្នកធ្វើល្អ!!!** អ្នកនឹងបានឃើញរូបគេប្រកបដោយការពេញចិត្ត ។ មនុស្សគ្រប់ៗរូបដែលស្គាល់គេ( ជនកតញ្ញូ) ដែលបានដឹងពីការធ្វើល្អរបស់គេ ឃើញពីទំនាក់ទំនងល្អរបស់គេចំពោះអ្នកមានគុណទាំងពីរ ឃើញពីការផ្តល់អ្វីៗទាំងអស់ដល់អ្នកមានគុណទាំងពីរដែលវាជាទីស្រឡាញ់របស់លោកទាំងពីរ ។ កូនប្រភេទនេះ ពេលណាហើយរូបគេជួបគ្រោះថ្នាក់ឬមានជំងឺតម្កាត់ផ្សេងៗ មនុស្សម្នាទាំងឡាយមានការអាណិតអាសូរដល់គេជានិច្ច ហើយពួកគេថែមទាំងជួយបួងសួងសុំពីអល់ឡោះអោយរូបគេបានចាកផុតពីគ្រោះចង្រៃ ហើយសូមអោយរូបគេជួបប្រទះតែសំណាងល្អ ។ ផលបុណ្យដែលគេបានទទួលទាំងនេះសំរាប់លោកីយ៏ប៉ុណ្ណោះ ដែលវាមិនទាន់ជាកន្លែង

ទទួលកុសលផលបុណ្យផងចុះទំរាំដល់ថ្ងៃបរលោកដែលវាជាកន្លែងទទួលការតបស្នងសងគុណវិញនោះ តើវាយ៉ាងណាទៅវិញ!!!

## ឱជនអកតញ្ញូ! ....ចូរអ្នករំលឹកឡើងវិញ :

- ម្តាយបានពរពោះអ្នក ហើយរូបអ្នកនៅក្នុងផ្ទៃរបស់លោកដែលជាគ្រោះថ្នាក់មួយក្នុងចំនោមគ្រោះថ្នាក់ធំៗផ្សេងៗទៀត! តើអ្នកមានអារម្មណ៍យ៉ាងណា?
- ម្តាយរបស់អ្នកសំរាលរូបអ្នកមក ក្នុងពេលរូបគាត់ឈឺចាប់ស្ទើរស្លាប់ ស្ទើររស់ ! តើអ្នកមានអារម្មណ៍យ៉ាងណា?
- ម្តាយរបស់អ្នកហូរឈាមចេញពីខ្លួនក្នុងពេលសំរាលរូបអ្នក និងក្រោយពេលសំរាលរួច! តើអ្នកមានអារម្មណ៍យ៉ាងណា?
- អ្នកបឺតជញ្ជក់យកឈាមរបស់ម្តាយក្នុងអំឡុងពេលនៅបៅ។ អ្នកម្តាយគ្រប់ៗរូបរីករាយនឹងការបំបៅកូនរបស់ខ្លួន ដែលយើងមិនអាចរកឃ្លាប្រយោគមកពណ៌នាពីក្តីមេត្តានោះបានឡើយ! តើអ្នកមានអារម្មណ៍យ៉ាងណា?
- ម្តាយរបស់អ្នកងូតទឹក សំអាតខ្លួនប្រាណ និងជំរះសំអាតសំលៀកបំពាក់ពីការប្រឡាក់ប្រឡូសអោយអ្នក! តើអ្នកមានអារម្មណ៍យ៉ាងណា?
- ម្តាយរបស់អ្នកមានក្តីបារម្ភបំផុតមកលើរូបអ្នកនៅពេលដែលអ្នកមានសភាពភ័យខ្លាច មានជម្ងឺឬមានអាការៈផ្សេងៗនោះ! តើអ្នកមានអារម្មណ៍យ៉ាងណា?
- ម្តាយរបស់អ្នកការពាររូបអ្នកនៅពេលមានសត្រូវចង់យាយីមកលើរូបអ្នក! តើអ្នកមានអារម្មណ៍យ៉ាងណា?
- ម្តាយរបស់អ្នកលះបង់គ្រប់បែបយ៉ាងសំរាប់ការរីកធំធាត់របស់អ្នក ទោះ



បីត្រូវគេហាមលោកពីការទទួលអាហារនិងទឹកឆ្អាញ់យ៉ាងណាក៏ដោយ! តើអ្នកមានអារម្មណ៍យ៉ាងណា?
- ម្តាយរបស់អ្នកយកចិត្តទុកដាក់ខ្ពស់បំផុតក្នុងការថែរក្សាពេលរូបអ្នកឈឺចុកចាប់ខ្លួនប្រាណនោះ! តើអ្នកមានអារម្មណ៍យ៉ាងណា?
- ឱជនអកតញ្ញូ ! អ្នកត្រូវរំលឹកដល់ពេលដែលឪពុកម្តាយរបស់អ្នកស្ទើរតែគ្មានពេលសំរាកព្រោះតែការស្វែងរកទ្រព្យសម្បត្តិដើម្បីការរស់រានរបស់អ្នកលោកអត់បានដេកស្ទើរតែរៀងរាល់ថ្ងៃនិងយប់! តើអ្នកមានអារម្មណ៍យ៉ាងណា?
-អ្នកមានគុណទាំងពីររបស់អ្នកយកចិត្តទុកដាក់បំផុតក្នុងការបង្ហាត់បង្រៀនដល់អ្នក ការកែតំរង់អ្នក និងការចង្អុលបង្ហាញអ្នកអោយឆ្ពោះទៅរកផ្លូវត្រូវទាំងក្នុងសាសនានិងក្នុងការរស់នៅលើលោកីយ៍នេះ! តើអ្នកមានអារម្មណ៍យ៉ាងណា?
- អ្នកមានគុណទាំងពីររបស់អ្នកដែលបានដាស់តឿនក្រើនរំលឹក ហើយលោកទាំងពីរសុខចិត្តទទួលរងនូវការលំបាកគ្រប់បែបយ៉ាងដើម្បីសេចក្តីសុខរបស់អ្នក! តើអ្នកមានអារម្មណ៍យ៉ាងណា?
- អ្នកមានគុណទាំងពីររបស់អ្នក នៅពេលលោកទាំងពីរមានការសប្បាយរីករាយចំពោះជោគជ័យរបស់អ្នក! តើអ្នកមានអារម្មណ៍យ៉ាងណា?
- អ្នកមានគុណទាំងពីររបស់អ្នក នៅពេលដែលលោកទាំងពីរការពាររូបអ្នកទាំងដៃនិងអណ្តាតរបស់គាត់! តើអ្នកមានអារម្មណ៍យ៉ាងណា?
- អ្នកមានគុណទាំងពីររបស់អ្នក នៅពេលដែលលោកទាំងពីរព្រួយបារម្ភបំផុតក្នុងពេលអ្នកយឺតយ៉ាវពីការវិលត្រឡប់មកផ្ទះ! តើអ្នកមានអារម្មណ៍យ៉ាងណា?

## ឱកូនអកតញ្ញូ! ចូរសញ្ជឹងគិតមើល

លោកអ្នកមានគុណទាំងពីរ មានកូនដែលចូលវ័យ២០ឆ្នាំហួយទៅហើយក្តីក៏លោកទាំងពីរសុខចិត្តលះបង់ពេលវេលាដើម្បីតាមឃ្លាំមើលនិងថែរក្សារូបអ្នក សុខចិត្តស្រេកឃ្លានខ្លួនឯងដើម្បីរូបអ្នកបានឆ្អែត សុខចិត្តខ្វះសំលៀកបំពាក់ខ្លួនឯងដើម្បីរូបអ្នកមានសំលៀកបំពាក់គ្រប់គ្រាន់ សុខចិត្តលំបាកសព្វបែបយ៉ាងដើម្បីរូបអ្នកមានសេចក្តីសុខ សុខចិត្តប្រកបការងារគ្រប់បែបយ៉ាងដើម្បីរូបអ្នកបានសំរាកកាយ បើអ្នកស្រេកទឹកពួកគាត់ចាក់ទឹកអោយ បើអ្នកឈឺពួកគាត់ព្យាបាលអ្នក បើអ្នកយំពួកគាត់លួងលោម បើអ្នកសើចពួកគាត់សប្បាយចិត្ត បើអ្នកក្រោកពីដំណេកពួកគាត់តាមមើល បើអ្នកអង្គុយពួកគាត់បួងសួងសុំសេចក្តីចំរើនដល់អ្នក!!!តើអ្នកគិតយ៉ាងណាចំពោះលោកមានគុណទាំងពីរនេះ ?តើលោកមានគុណទាំងពីរនេះគួរបានផលបែបណា ? តើលោកមានគុណទាំងពីរនេះសក្តិសមទទួលការតបស្នងសងគុណអ្វីខ្លះពីរូបអ្នក ឱកូនអកតញ្ញូ ?

## ប្រវត្តិរឿងជនអកតញ្ញូមួយចំនួន

នេះជារឿងពិតមួយចំនួនដែលគេលើកមកបញ្ជាក់ ដើម្បីដាស់សតិជនអកតញ្ញូពីលទ្ធផលចុងក្រោយរបស់គេ និងបាបកម្មដ៏ធំបំផុតសំរាប់ទង្វើដែលគេបានប្រព្រឹត្ត :

១- គេបានបញ្ជាក់ពីរឿងពិតមួយថាៈ កូនអកតញ្ញូម្នាក់បានយកជើងធាក់ឪពុករបស់ខ្លួនខ្ទាតទៅដល់មាត់ទ្វារ ដើម្បីដេញឪពុកអោយចេញផុតពីផ្ទះ។



បុរសជាឪពុក( ធ្លាប់ធ្វើអំពើ អាក្រក់ចំពោះឪពុករបស់ខ្លួន) កូនអកតញ្ញូម្នាក់នេះ ក្រោយមកគេមានកូនអកតញ្ញូម្នាក់ខ្លាំងជាងខ្លួនទៅទៀត ព្រោះកូនរបស់គេបានធាក់គេអោយធ្លាក់ទៅលើផ្លូវសាធារណៈ ខណៈនោះគេបាននិយាយទៅកាន់កូនរបស់ខ្លួនថាៈ ឈប់សិន! កាលអញធាក់ឪពុករបស់អញគឺត្រឹមនេះទេ( ត្រឹមមាត់ទ្វារ) ? កូនបុរសអកតញ្ញូបានតបទៅកាន់ឪពុកអកតញ្ញូរបស់ខ្លួនថាៈនេះហើយជាការតបស្នងសំរាប់ផលកម្មរបស់ឪពុក! ។

មិត្តអ្នកអានជាទីស្រលាញ់! សូមតាមដានរឿងនិទានពិតជាក់ស្តែងមួយនេះ អ្នកនឹងបានឃើញយ៉ាងច្បាស់ថាៈ ជីវិតគឺជាបំណុលនិងសំណង ពោលគឺផលកម្មដែលត្រូវទទួលបានគឺតាមរយៈទង្វើរបស់ខ្លួន? ពិតណាស់បើអ្នកប្រព្រឹត្តបាបកម្មពៀរ កម្មពៀរនោះនឹងវិលមករកអ្នកវិញមិនខាន។ ដូចនេះអ្នកត្រូវតែធ្វើល្អចំពោះឪពុកម្តាយរបស់អ្នក នោះកូនចៅរបស់អ្នកនឹងធ្វើល្អចំពោះអ្នកវិញជាមិនខាន។

២- គេបានបញ្ជាក់ពីរឿងពិតមួយថាៈ មានយុវជនម្នាក់បណ្តោយខ្លួនអោយរសាត់អណ្តែតតាមសេចក្តីភ្លើតភ្លើនដែលមិនអាចដកខ្លួនចេញពីអំពើដ៏ថោកទាបនោះបានឡើយ ។ចំណែកឯឪពុករបស់គេវិញជាអ្នកប្រកាន់ខ្ជាប់នូវសាសនាអ៊ីស្លាមដែលគាត់តែងតែព្យាយាមណែនាំដាស់តឿនក្រើនរំលឹកដល់កូនរបស់គាត់។ ឪពុកតែងតែណែនាំកូនថាៈ( ឱកូនសំលាញ់! ឪពុកសូមរំលឹកកូនថាៈ កូនត្រូវប្រុងប្រយ័ត្នពីសេចក្តីភ្លើតភ្លើនរបស់យុវជន! ព្រោះភាពខ្លាំងក្លា និងកំហឹងគឺក្រោមការគ្រប់គ្រងរបស់អល់ឡោះទាំងអស់! កូនត្រូវតែដកខ្លួនអោយឆ្ងាយពីបណ្តាជនបំពានទាំងនោះ) ។សូមបញ្ជាក់ថាពេលណាឪពុកដាស់តឿន

រំលឹកកូនរូបនេះកាន់តែបង្កើននូវអំពើអកតញ្ញូ និងធ្វើអំពើបំពានមកលើឪពុករបស់គេកាន់តែខ្លាំងឡើងៗ។ នៅថ្ងៃមួយឪពុកបាននិយាយដាស់តឿនទៀត ស្រាប់តែកូនអកតញ្ញូរូបនោះ លើកដៃរកវាយឪពុករបស់ខ្លួន។ ពេលនោះឪពុកក៏ស្បថសច្ចានឹងអល់ឡោះថានឹងព្យាយាមធ្វើដំណើរទៅកាន់ហ្គៃទុលឡោះអាល់ហារ៉ម( កាក់ហ្ពះ) ។ ពេលទៅដល់ទីនោះ គាត់តោងជញ្ជាំងកាក់ហ្ពះ ហើយបួងសួងសុំពីអល់ឡោះអោយទ្រង់ដាក់ទណ្ឌកម្មលើកូនរបស់គាត់ដោយពាក្យបួងសួងសុំជាលក្ខណៈកំណាព្យថា: *ឱម្ចាស់ដែលអ្នកធ្វើហាជ្ជីទាំងអស់មករកទាំងអ្នកជិត និងអ្នកឆ្ងាយរូបខ្ញុំក៏មករកទ្រង់ដែរ ឱម្ចាស់តែមួយ!ដែលមិនបដិសេធអ្នកដែលមកបួងសួងសុំពីទ្រង់នេះជាទីកន្លែងសំរាប់អ្នកធ្វើអំពើអាក្រក់មកលើខ្ញុំមិនអាចគេចផុតសូមទ្រង់ផ្តល់ភាពយុត្តិធមិអោយខ្ញុំពីអំពើកូនខ្ញុំផង ដោយអំណាចរបស់ទ្រង់សូមអោយវាស្លាប់មួយចំហៀងខ្លួនចុះ ឱអ្នកដែលមហាអស្ចារ្យ! ដែលគ្មានអ្នកប្រសូត និងគ្មានការប្រសូត !!!*

**គេបាននិយាយថា:** ឪពុកមិនទាន់ទាំងបញ្ចប់ពាក្យបួងសួងសុំរបស់គាត់ផង ស្រាប់តែកូនរបស់គាត់ប្រេះឆ្អឹងជំនីរខាងស្តាំទៅហើយ។

**៣-** គេបានបញ្ជាក់ពីរឿងពិតមួយថា: មានកូនប្រុសម្នាក់បានយកម្តាយរបស់ខ្លួនទៅទុកចោលក្នុងមណ្ឌលចាស់ជរាមួយ ដោយរូបគេមិនទៅក្បែរដើម្បីសួរសុខទុក្ខម្តាយជាច្រើនឆ្នាំមកហើយ មិនតែប៉ុណ្ណោះ សូម្បីតែទូរស័ព្ទសាកសួរពីសុខទុក្ខគាត់ក៏គ្មានដែរ។ ម្តាយបានស្នើសុំអ្នកគ្រប់គ្រងមណ្ឌលអោយជួយទាក់ទងកូនរបស់គាត់ដើម្បីគាត់បានឃើញមុខកូន បានអោបកូនជាប់



នឹងដើមទ្រូង និងបានថើបកូនមុននឹងគាត់ស្លាប់! ទឹកភ្នែករបស់គាត់ហូរមកហើយគាត់នៅតែហៅឈ្មោះកូនរបស់គាត់ជាប់មាត់មុនគាត់មកជួប អ្នកទទួលខុសត្រូវក្នុងមណ្ឌល។ ពេលនោះអ្នកទទួលខុសត្រូវក្នុងមណ្ឌលចាស់ជរាក៏បានភ្ជាប់ទូរស័ព្ទទៅកូនរបស់គាត់ដោយប្រាប់ថាម្តាយរបស់អ្នកជិតដល់សង្ខារហើយ ហើយគាត់ចង់ឃើញរូបអ្នក ចង់អោបថើបអ្នកមុនគាត់ដាច់ដង្ហើម។ ប៉ុន្តែកូនអកតញ្ញូរូបនោះបានបដិសេធហើយនិយាយថា : គេគ្មានពេលវេលាទំនេរទេ ដោយគេមានការងាររវល់ខ្លាំងណាស់ គេមានការមមាញឹកក្នុងការងារជំនួញ និងអចលនៈទ្រព្យជាច្រើន ហើយគេក៏បិទទូរស័ព្ទទៅ។ លុះពេលម្តាយគេបានស្លាប់ អ្នកទទួលខុសត្រូវក្នុងមណ្ឌលបានទូរស័ទ្ទទៅកាន់កូនអកតញ្ញូរូបនោះប្រាប់ពីមរណភាពរបស់ម្តាយគេ ។កូនអកតញ្ញូរូបនោះបានឆ្លើយមកវិញថា:ចូរបំពេញបែបបទអោយគាត់ រួចកប់គាត់ក្នុងផ្នូររបស់គាត់ទៅ! ។

មិត្តអ្នកអានជាទីស្រលាញ់! ពេលណាយើងរំលឹកដល់ប្រវត្តិរឿងនេះ ធ្វើអោយដើមទ្រូងស្ទើរប្រេះបែក និងពេលណាស្តាប់ប្រវត្តិរឿងនេះធ្វើអោយខ្លួនប្រាណញាប់ញ័រនិងសោកស្តាយជាពន់ពេក ចិត្តអាចបង្ហាញពីភាពរឹងរូសដូចដុំថ្ម និងទន់ជ្រាយដូចសំឡី ភ្នែកឡើងក្រហមលាយឡំដោយតំណក់ទឹកភ្នែក។

## ការក្រើនរំលឹករបស់លោកអ៊ិបនូអាល់ជៅហ្ស៊ីចំពោះជនអកតញ្ញូ

លោកអ៊ិបនូជៅហ្ស៊ីបានរំលឹកថា: ឱអ្នកដែលព្រងើយកន្តើយចំពោះការបំពេញកាតព្វកិច្ចរបស់ខ្លួន! ឱអ្នកដែលប្តូរការធ្វើអំពើល្អចំពោះឪពុកម្តាយយកអំពើអកតញ្ញូ! ឱអ្នកដែលភ្លេចកាតព្វកិច្ចរបស់ខ្លួន! ឱអ្នកដែលធ្វេស

ប្រហែលសភារកិច្ចចំពោះមុខ! អ្នកត្រូវដឹងថាៈ ការធ្វើអំពើល្អចំពោះឪពុកម្ដាយ គឺជាបំណុលមួយដែលជាបន្ទុករបស់អ្នក! អ្នកកំពុងបណ្ដោយខ្លួនរបស់អ្នក ដើរតាមកំហុសឆ្គងដ៏សែនអាម៉ាស់មួយហើយ!!! អ្នកចង់បានឋានសួគ៌មែន ទេ? អ្នកត្រូវដឹងថាឋានសួគ៌គឺស្ថិតក្រោមបាតជើងម្ដាយរបស់អ្នក( ការយល់ ព្រមរបស់ម្ដាយស្របតាមច្បាប់អ៊ិស្លាម គឺជាចំណងមួយយ៉ាងសំខាន់បំផុត ក្នុងបញ្ហានេះ) ។ រយៈពេល៩ខែដែលរូបអ្នកនៅក្នុងផ្ទៃរបស់លោកហាក់បី ដូចរយៈពេល៩ឆ្នាំ ?

អ្នកម្ដាយរងនូវការឈឺចាប់ក្នុងពេលសំរាលរូបអ្នកស្ទើរដាច់ដង្ហើម អ្នកម្ដាយ បានបំបៅរូបអ្នកដោយទឹកដោះផ្ទាល់អ្នកម្ដាយស៊ូទ្រាំអត់ងងុយដើម្បីរូបអ្នក អ្នកម្ដាយបានយកដៃស្ដាំរបស់លោកដុសលាងសំអាតរូបអ្នក អ្នកម្ដាយស៊ូទ្រាំ អត់អាហារដើម្បីរូបអ្នក អ្នកម្ដាយបានរៀបចំទីសំរាករបស់លោកជាជាកន្លែង សុខដុមរមនារបស់អ្នក អ្នកម្ដាយលះបង់អ្វីៗក៏ដើម្បីរូបអ្នក អ្នកម្ដាយសែន ព្រួយពេលអ្នកមានជំងឺ រហូតទ្រហោរយំដោយសាររូបកូន អ្នកម្ដាយលះ បង់សម្បត្តិអ្វីៗក៏ដើម្បីសុខភាពរូបកូន *បើគេដាក់ជំរើសអោយអ្នកម្ដាយជ្រើស រើសយកការរស់របស់រូបអ្នក និងសេចក្ដីស្លាប់របស់គាត់ ច្បាស់ជាអ្នក ម្ដាយស្រែកបញ្ចោក់ដោយសំលេងខ្លាំងៗថាៈ គឺជ្រើសរើសយកការរស់ របស់កូនពុំខានឡើយ!!!*

-ហ្ហែ!អ្នកបានបញ្ចេញអកប្បកិរិយាមិនសក្ដិសមដាក់អ្នកម្ដាយច្រើនដងមក ហើយ តែអ្នកម្ដាយនៅតែបានឆ្លៀតបួងសួងសុំពីអល់ឡោះអោយរូបអ្នក ជួបតែសំណាងល្អគ្រប់ពេលវេលា!



-ហ្ហែ! ពេលអ្នកម្ដាយត្រូវការរូបអ្នកក្នុងពេលលោកចូលវ័យជរា រូបអ្នកបែរ ថាមិនសូវចាប់អារម្មណ៍ចំពោះលោកឡើយ ។

-ហ្ហែ! ពេលរូបអ្នកបានឆ្អែត ពេលនោះអ្នកម្ដាយនៅឃ្លាន ពេលរូបអ្នកត្រូវ ការអ្នកម្ដាយ អ្នកម្ដាយបំពេញចិត្តភ្លាម អ្នកម្ដាយគិតគូររូបកូនជាងខ្លួនគាត់ តើរូបអ្នកគួរបំភ្លេចគាត់ដែរឬទេ!!! អ្នកជួបការលំបាកតិចណាស់ បើប្រៀប ធៀបនឹងអ្នកម្ដាយ អ្នកម្ដាយចំណាយជីវិតដ៏ខ្លីនេះដើម្បីរូបអ្នក អ្នកម្ដាយ លះបង់អ្វីៗដើម្បីរូបអ្នក ។

នេះហើយអល់ឡោះជាម្ចាស់បានហាមឃាត់អ្នកក្នុងការពោលពាក្យថា " អ៊ិសអ៊ុះ (ទៅកាន់ឪពុកម្ដាយ)" ហើយអំពើដ៏ព្រៃផ្សៃរបស់អ្នកចំពោះម្ដាយ របស់អ្នកនឹងមានបាបកម្ម និងកម្មពៀរមកលើរូបអ្នកជារៀងរហូត ។អ្នកនឹង ទទួលទណ្ឌកម្មនិងកម្មពៀរនៅលើលោកីយ៍នេះពីសំណាក់បណ្ដាកូនអកតញ្ញូ របស់អ្នកវិញជាមិនខាន ។ អ្នកនឹងឃ្លាតឆ្ងាយអំពីការអាណិតអាសូររបស់ អល់ឡោះជាមិនខាន ។

ឱអល់ឡោះជាម្ចាស់! សូមទ្រង់ដាក់រូបយើងខ្ញុំជាអ្នកកតញ្ញូចំពោះមាតា បិតារបស់យើងខ្ញុំទាំងពេលនៅមានជីវិត និងក្រោយពេលគាត់ទទួលមរណៈ ភាពផង ។ សូមទ្រង់អភ័យទោសដល់យើងខ្ញុំ និងមាតាបិតារបស់យើងខ្ញុំ ហើយ និងបណ្ដាជនមូស្លីមទាំងឡាយផង ។ យើងខ្ញុំសូមបួងសួងដល់ទ្រង់ចង្អុល បង្ហាញដល់យើងខ្ញុំចំពោះការកតញ្ញូនិងធ្វើអំពើល្អចំពោះមាតាបិតាផងចុះ ។

وصلى الله على نبينا محمد وعلى آله وأصحابه أجمعين.